# ខ្មែរប៉ុស្តិ៍
ឆ្នេរខាងកើត
# THE KHMER POST
EAST COAST
The Cambodian-American Biweekly News
Email : Khmerpostusa@gmail.com
Call : (267) 253-3947
VOLUME 04 ISSUE 57 April 09th - 22th, 2010







## ព្យុហយាត្រាដើម្បីផ្លាស់ប្តូរច្បាប់អន្តោប្រវេសន៍




**ដោយ : សារិត សំ**

វ៉ាស៊ីនតោនឌីស៊ី : ប្រធានសហគមន៍ខ្មែរ បុគ្គលិក និងនាយិកានៃសហគមន៍ខ្មែរ ក្រុងហ្វីឡាដែលហ្វៀ និងមានបងប្អូនខ្មែរប្រមាណ៧០នាក់ មានអ្នកធ្វើការនៅសាលា និងឧបាសក ឧបាសិកា វត្តព្រះពុទ្ធរង្សី

(តទៅទំព័រទី ១២)

### មាតិការឿង ទំព័រ


១- ពិធីរំលឹកខួប....................ទំព័រទី០៣
២- កិច្ចសម្ភាសន៍.................ទំព័រទី០៤
៣- រស់ យីន.........................ទំព័រទី០៥
៤- ក្តីស្នេហ៍គ្មានទីបញ្ចប់..........ទំព័រទី០៦
៥- The Cambodia............ទំព័រទី០៨-១៣
៦- សីហមុនី..........................ទំព័រទី១២
៧- អាថ៌កំបាំង.......................ទំព័រទី១៤
៨- នាទីប្រវត្តិសាស្ត្រ.............ទំព័រទី១៥
៩- ស្ត្រីខ្មែរជំបូងបង្អស់...........ទំព័រទី១៦
១០- ហោរាសាស្ត្រ...............ទំព័រទី១៧


សូមអញ្ជើញលោកអ្នកអានអត្ថបទជាភាសាអង់គ្លេសនៅទំព័រខាងក្នុង ដែលបានដកស្រង់ និងទទួលការអនុញ្ញាតឱ្យចុះផ្សាយពីសារព័ត៌មាន The Cambodia Daily នៅប្រទេសកម្ពុជា ។












# ពិធីរំលឹកខួបនៃព្រឹត្តិការណ៍ផ្ទុះគ្រាប់បែកកាលពីថ្ងៃទី៣០ មីនា ១៩៩៧

CEN : សុភ័ក្រ្ត

•••ក្រុមគ្រួសារជនរងគ្រោះ និងអ្នកស្លាប់ក្នុងព្រឹត្តិការណ៍ផ្ទុះគ្រាប់បែកកាលពីថ្ងៃទី30 ខែ មីនា ឆ្នាំ 1997 នៅតែទន្ទឹងរង់ចាំយុត្តិធម៌ ដែលមានរយៈពេល 13ឆ្នាំហើយ ។

ដើម្បីធ្វើពិធីរម្លឹកខួប13ឆ្នាំនៃព្រឹត្តិការណ៍វាយប្រហារដោយគ្រាប់បែកដៃលើក្រុមបាតុករ ដែលដឹកនាំដោយលោក សម រង្ស៊ី កាលពីថ្ងៃទី 30 ខែមីនា ឆ្នាំ1997 គណបក្ស សម រង្ស៊ី បានរៀបចំពិធីជួបជុំមួយនៅចេតិយមុខអតីតវិមានរដ្ឋសភាខាងត្បូងព្រះបរមរាជវាំង ។ ជាទីដែលតម្កល់ធាតុអ្នកស្លាប់ដោយព្រឹត្តិការណ៍ផ្ទុះគ្រាប់បែក ដែលយ៉ាងហោចណាស់មានមនុស្ស16នាក់បានស្លាប់ និងជាង100នាក់ផ្សេងទៀតរងរបួស ។ ក៏ប៉ុន្តែជនល្មើសពុំទាន់ត្រូវបានចាប់ខ្លួនយកមកកាត់ទោសនៅឡើយទេ ។



ស្ត្រីតំណាងក្រុមគ្រួសារអ្នកស្លាប់ និងអ្នករបួសបានថ្លែងក្នុងពិធីរម្លឹកខួបនៅព្រឹកថ្ងៃទី30 ខែមីនានេះថា យើងខ្ញុំទាំងអស់គ្នាបានរង់ចាំយុត្តិធម៌ទាំងអំណត់អស់រយៈពេល13ឆ្នាំហើយ ដែលឃាតករមិនត្រូវបានចាប់ខ្លួនទេ ។ យើងខ្ញុំសូមអំពាវនាវជាថ្មីម្តងទៀតចំពោះរដ្ឋាភិបាលកម្ពុជា មេត្តាបើកការស៊ើបអង្កេតលើឧក្រិដ្ឋកម្មបោកប្រាប់បែកនេះ ដើម្បីរកមុខឃាតករ និងអ្នកនៅពីក្រោយខ្នងយកទៅផ្តន្ទាទោស ។

ស្ត្រីរូបនេះក៏អំពាវនាវដល់ភ្នាក់ងារស៊ើបអង្កេតសហរដ្ឋអាមេរិក FBI ដើម្បីបើកការស៊ើបអង្កេតជាថ្មីលើសំណុំរឿងក្តីឧក្រិដ្ឋនេះ ។

ចំណែកលោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី ដែលរងរបួសក្នុងព្រឹត្តិការណ៍ផ្ទុះគ្រាប់បែកនោះ ក៏បានថ្លែងពីប្រទេសបារាំង តាមទូរស័ព្ទចូលមកកាន់អង្គពិធីថា លោកមានជំនឿថា យុត្តិធម៌ត្រូវតែឈ្នះថ្ងៃណាមួយ យើងនឹងលាតត្រដាងការពិតឱ្យមតិសាធារណៈជនអន្តរជាតិ និងជាតិបានឃើញបានយល់យ៉ាងច្បាស់ថា អ្នកមានអំណាច អ្នកដែលកាន់តំណែងខ្ពស់បំផុត គឺពាក់ព័ន្ធការគប់គ្រាប់បែកយ៉ាងកំសាកមកលើបាតុករអ្នកស្លូតត្រង់ កាលពីថ្ងៃទី30 ខែមីនា ឆ្នាំ1997 ។ ក្រុមបាតុករបានទាមទារឱ្យប្រព័ន្ធតុលាការឯករាជ្យកាត់ក្តីដោយមិនពុករលួយ និងកាត់ក្តីដោយឈរលើគតិយុត្តិធម៌ ។

មេដឹកនាំគណបក្សប្រឆាំងក៏បានជម្រុញជាដដែលៗឱ្យអាជ្ញាធរមានសមត្ថកិច្ចរកមុខ ចាប់ខ្លួនជនដៃដល់ និងអ្នកប្រព្រឹត្តមកផ្តន្ទាទោសតាមច្បាប់ចំពោះព្រឹត្តិការណ៍នៃការបោកគ្រាប់បែកលើហ្វូងបាតុករកាលពីថ្ងៃទី30 ខែមីនា ឆ្នាំ1997 ។

យ៉ាងណាក៏ដោយលោក ទិត សុធា ទីប្រឹក្សារាជរដ្ឋាភិបាល និងជាអ្នកនាំពាក្យអង្គភាព ព័ត៌មាន និងប្រតិកម្មរហ័សរបស់ទីស្តីការគណៈរដ្ឋមន្ត្រី បានលើកឡើងថា រហូតមកដល់ពេលនេះរាជរដ្ឋាភិបាលកម្ពុជានៅមិនទាន់បិទសំណុំរឿងឧក្រិដ្ឋកម្មគប់គ្រាប់បែកថ្ងៃទី30 ខែមីនា ឆ្នាំ1997នោះទេ គឺសមត្ថកិច្ចកំពុងបន្តការស៊ើបអង្កេតតាមចាប់ឃាតករ និងអ្នកពាក់ព័ន្ធមកឱ្យតុលាការកាត់ទោស ។

លោក ទិត សុធា បានបន្ថែមថា កន្លងមកលោក សម រង្ស៊ី ធ្លាប់បានសរសេរលិខិតសុំទោសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយបានបញ្ជាក់ថា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ពុំមានពាក់ព័ន្ធនឹងករណីគប់គ្រាប់បែកកាលពីថ្ងៃទី30 មីនា 1997 ដូចការចោទប្រកាន់ពីមុនរបស់លោកឡើយ ។

សូមរម្លឹកថា ព្រឹត្តិការណ៍បោកគ្រាប់បែកលើក្រុមបាតុករដែលដឹកនាំដោយលោក សម រង្ស៊ី កាលពីថ្ងៃទី 30 ខែមីនា ឆ្នាំ1997 ត្រូវបានទីភ្នាក់ងារស៊ើបអង្កេតសហរដ្ឋអាមេរិក FBI បានបើកការស៊ើបអង្កេតភ្លាមៗ ។ ក៏ប៉ុន្តែការស៊ើបអង្កេតនោះមិនទទួលបានលទ្ធផលឈានដល់ការចាប់ខ្លួនជនដែលបោកគ្រាប់បែកទេ គឺបានត្រឹមតែសម្ភាសន៍សាក្សី និងក្រុមប៉ូលិសកម្ពុជាប៉ុណ្ណោះ ។

តាមរបាយការណ៍ស៊ើបអង្កេតរបស់ FBI ដែលបានចេញផ្សាយនាពេលថ្មីៗនេះ បានបង្ហាញថា ភ្នាក់ងារស៊ើបអង្កេត FBI បីរូប បានបង្ខំចិត្ត ចាកចេញពីកម្ពុជាដោយសារតែគ្មានកិច្ចសហការពីអាជ្ញាធរកម្ពុជា ។

ក៏ប៉ុន្តែអាជ្ញាធរប៉ូលិសកម្ពុជា បានបដិសេធនឹងការលើកឡើងរបស់ FBIហើយថា ភ្នាក់ងារ FBI ខ្លួនឯងទេដែលអសមត្ថភាពស្វែងរកមិនឃើញការពិត និងបានដកថយទៅវិញដោយខ្លួនឯង ៕

# ឈាមស្រស់ក្រុមអាវក្រហមថៃបានចាក់សាចពេញថ្នល់ក្រុងបាងកក

ដោយ : ម៉ម យ៉ឺន

•••ក្រោយពីលោក អភិស៊ិត វេជ្ជាជីវ៉ាក់ ប្រធានគណបក្សប្រជាធិប៉ាត់ បានកាន់តំណែងជានាយករដ្ឋមន្ត្រីថៃ ក្នុងរយៈពេលជាង១ឆ្នាំ ៣ខែកន្លងមកបញ្ហាវិបត្តិនយោបាយថៃ មិនបានដោះស្រាយឱ្យជ្រះស្រឡះទៅបានទេ ។

ពិតមែនតែក្រុមអាវលឿង បានបញ្ឈប់មហាបាតកម្មប្រឆាំងកាលពីជំនាន់រដ្ឋាភិបាល លោក ថាក់ស៊ិន ជិនណាវ៉ាត់ លុះឥឡូវក្រុមនេះបានក្លាយទៅជាក្រុមគាំទ្ររដ្ឋាភិបាលថ្មី លោក អភិស៊ិត ទៅវិញ។

ចំណែកគណបក្សអ្នកនិយមលោក ថាក់ស៊ិន ត្រូវបានក្លាយទៅជាក្រុមប្រឆាំងនឹងរដ្ឋាភិបាលវិញម្តង ហើយបានបន្តធ្វើបាតុកម្មប្រឆាំងយ៉ាងតក្រឹកតគ្រេងមកទៀត ។ ប៉ុន្តែបានបញ្ចេញសកម្មភាពជាមហាបាតុកម្មប្រកបដោយហឹង្សា បានប្រើអាវុធសង្គ្រាមបាញ់ប្រហារក៏មាន មានការវាយកំទេចរថយន្តតូចធំក៏មាន និងដុតបំផ្លាញចោលអស់ជាច្រើនគ្រឿងក៏មាន មានវាយដំច្រំធាក់ទៅលើបុគ្គលិករាជការ និងបណ្តាជនមួយចំនួនក៏មាន រហូតដល់មានការកំហែងគម្រាមដល់អាយុជីវិតនៃលោកនាយករដ្ឋមន្ត្រី អភិស៊ិត ថែមទៀតផង ។

លោក ថាក់ស៊ិន បានត្រូវតុលាការកំពូលថៃកាត់ទោសឱ្យជាប់គុក និងពេលថ្មីៗនេះ បានកាត់សេចក្តីសម្រេចដកហូតលុយ និងទ្រព្យសម្បត្តិ ដែលបានមកដោយខុសច្បាប់ចំនួនជាង ១ពាន់៤រយលានដុល្លារ យកទៅទុកជាសម្បត្តិរដ្ឋ ។ សកម្មភាពនេះបានបណ្តាលឱ្យលោក ថាក់ស៊ិន និងក្រុមអាវក្រហមកើតមានប្រតិកម្មជាកំហឹង ប្រៀបដូចជាកំរិតកំដៅភ្លើងខ្ពស់ដល់ ១ពាន់អង្សា គួរឱ្យភ័យខ្លាច ។

បន្ទាប់មកលោក ថាក់ស៊ិន ត្រូវតែចេញបទបញ្ជាទៅដល់ក្រុមអាវក្រហម ឱ្យប្រមែប្រមូលក្រុមបាតុករឱ្យបានចំនួនរាប់លាននាក់ ដោយបានសន្យាថា "នឹងចំណាយលុយជាច្រើនរយលានយកមកជួយ



ក្រុមអាវក្រហមយកឈាមដើរលាប និងចាក់សាចក្នុងក្រុងបាងកក



ក្រុមអាវក្រហមបូមឈាម ត្រៀមលាបមុខ នៅមុខទីស្នាក់ការរដ្ឋាភិបាល

បាតុករក្នុងម្នាក់ ក្នុង១ថ្ងៃ ២ពាន់បាត្រ រួចហើយឱ្យដើរសំដៅទៅទីក្រុងបាងកក នៅក្នុងអំឡុងពេលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០ នេះតទៅ " ។

លោក ថាក់ស៊ិន បានចេញបញ្ជាថា " នៅពេលណាមហាបាតុករដើរចូលទៅទីក្រុងបាងកក ហើយត្រូវកងទ័ពបាញ់បណ្តាលឱ្យបង្ហូរឈាម ពេលនោះរូបខ្ញុំ ថាក់ស៊ិន នឹងចូលមកដើរនាំមុខមហាបាតុករទៅមុខទៀត មួយរំពេចដែរ" ។ បញ្ហានេះ បានស្រែកបំពងផ្សព្វផ្សាយពេញប្រទេសថៃ និងពេញពិភពលោក ដូច្នេះហើយ បានជាគេសង្កេតឃើញក្រុមបាតុករអាវក្រហមជាច្រើនម៉ឺននាក់ បានដើរចេញមកប្រមូលផ្តុំគ្នាពីគ្រប់បណ្តាខេត្តនានា តាមរថយន្តតូចធំ និងតាមកាណូតរាប់ពាន់គ្រឿងមកកាន់ទីក្រុងបាងកក រួចហើយនាំគ្នាទៅប្រមូលផ្តុំគ្នានៅតាមចំណុចសំខាន់ៗ ដែលមេបាតុករបានកំណត់ឱ្យ ។

ចំណែកខាងរដ្ឋាភិបាល ក្រោយពីបានទទួលដំណឹងពីគម្រោងលោក ថាក់ស៊ិន និងក្រុមអាវក្រហមហើយ ក៏បានចាត់វិធានការណ៍រៀបចំការពារសន្តិសុខ និងរបៀបរៀបរយនៅគ្រប់ទីស្នាក់ការរដ្ឋ និងមន្ទីរសំខាន់ៗទាំងអស់ ដោយប្រើកងតម្រួតរក្សាសន្តិសុខ សហការគ្នាជាមួយកងអាសាស្ម័គ្រ ។ បើសិនជាក្រុមអាវក្រហម មានប្រើអំពើហឹង្សាខ្លាំងក្លា រដ្ឋាភិបាលត្រូវតែសុំអន្តរាគមន៍ពីកងទ័ពជាតិឱ្យជួយបំបែកកម្លាំងក្រុមបាតកម្មទាំងនោះដែរ ដោយចាត់ទុកថា ជាក្រុមភេរវជនបង្កវិនាសកម្មបំផ្លិចបំផ្លាញសម្បត្តិរដ្ឋ និងសាធារណជន និងធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពនៃបណ្តាជនទូទៅ ដែលពុំបានចូលរួមក្នុងសកម្មភាពដ៏ហឹង្សាទាំងនោះ ។

ថ្ងៃទី១២ ខែមីនា ក្បួនមហាបាតុកម្មក្រុមអាវក្រហម បានផ្តើមដើរសំដៅទៅទីក្រុងបាងកកយ៉ាងសន្សឹមៗ ប្រៀបដូចចលនាដុំរងើកភ្លើងតូចៗ កំពុងប្រមូលផ្តុំគ្នា ឱ្យកើតទៅជាដុំភ្លើងដ៏ធំ ឆេះក្រហមពេញទីក្រុងទាំងមូល ក្រុមអាវក្រហមបានស្រែកតវ៉ាទាមទារឱ្យនាយករដ្ឋមន្ត្រី អភិស៊ិត រំលាយរដ្ឋសភា រួចហើយចុះចេញពីតំណែង ។ ប៉ុន្តែលោក អភិស៊ិត បានថ្លែងប្រាប់ប្រជាពលរដ្ឋថៃថា លោកពុំអាចធ្វើតាមពាក្យតវ៉ាទាមទារ ដោយមិនសមហេតុផលនេះទៅបានទេ ហើយលោកអំពាវនាវទៅក្រុមមហាបាតុករថា ត្រូវតែរក្សាការប្រជុំបាតុកម្មដោយសន្តិវិធី អហឹង្សា និងមានរបៀបរៀបរយទៅតាមច្បាប់រដ្ឋធម្មនុញ្ញបានចែង ។

ពីថ្ងៃទី១២ មីនា មកដល់ថ្ងៃទី១៦ មីនា ២០១០ មហាបាតុកម្មបានប្រព្រឹត្តទៅដោយពុំមានឃើញសភាពហឹង្សា ឬប៉ះទង្គិចគ្នាជាមួយក្រុមរក្សាសន្តិសុខរបៀបរៀបរយទេ គឺគ្រាន់តែមានការថ្លែង ទាំងលោក ថាក់ស៊ិន ទាំងលោកមេដឹកនាំក្រុមអាវក្រហម ឱ្យមហាជនចេញពីគ្រប់ភូមិស្រុកមក ដើម្បីរួមកម្លាំងគ្នា ស្រែកទាមទារឱ្យលោក អភិស៊ិត ចុះចេញតំណែង និងរំលាយរដ្ឋសភាចោល បើមិនធ្វើដូច្នេះទេ គេនឹងប្រើយុទ្ធវិធីថ្មីមួយទៀត គឺចាក់បូមយកឈាមស្រស់ពីបណ្តាលបាតុករចំនួន១សែននាក់ ក្នុងម្នាក់ៗឱ្យបានពី៣ទៅ៥ស្លាបព្រាបាយ ។

ការបូមឈាមស្រស់នេះ ត្រូវបានប្រព្រឹត្តទៅចាប់តាំងពីថ្ងៃទី១៦ មីនា បន្ទាប់មកគេឃើញក្រុមអាវក្រហម (តទៅទំព័រទី ១៨)

# កិច្ចសម្ភាសន៍រវាងខ្មែរប៉ុស្តិ៍ជាមួយប្រធានគណបក្សសិទ្ធិមនុស្ស

**ដោយ : អ៊ឹម លឿម**

កឹម សុខា : បច្ចុប្បន្នកម្ពុជារីកចម្រើនជាងរបប ប៉ុល ពត

អ៊ឹម លឿម : ក្នុងនាមកាសែតខ្មែរ ខ្ញុំបាទសូមជំរាបសួរ តើឯកឧត្តមសុខសប្បាយជាទេបាទ ! ?

កឹម សុខា : អរគុណណាស់ សុខសប្បាយធម្មតាទេបាទ ! ។

អ៊ឹម លឿម : តាមដែលខ្ញុំនៅចាំបាន រំលងទើបតែបានជាងមួយខែសោះ ឯកឧត្តមបានអញ្ជើញមកកាន់សហរដ្ឋអាមេរិកជាថ្មីម្តងទៀត តើការអញ្ជើញមកកាន់សហរដ្ឋអាមេរិកក្នុងពេលនេះ ឯកឧត្តមផ្តោតទៅលើកត្តាសំខាន់ៗអ្វីខ្លះបាទ ?

កឹម សុខា : គោលបំណងរបស់ខ្ញុំមកជាលើកទីពីរនេះដោយសារមានបងប្អូនខ្មែរយើងនៅរដ្ឋមួយចំនួន ដែលខ្ញុំមកលើកមុនមិនបានដើរគ្រប់ ដោយសារលើកមុនខ្ញុំមានពេលតែប្រាំសប្តាហ៍ ហើយដើរបានតែប្រាំបួនរដ្ឋ ហើយមានរដ្ឋមួយចំនួនទៀត ដូចជា អ៊ីលីណយ (ឈីកាហ្គោ) ជាកន្លែងដែលខ្ញុំមិនទាន់បានទៅ ហើយខ្ញុំមានការអញ្ជើញពីប្រជាពលរដ្ឋនៅកន្លែងនោះ បានយើងទៅជួបជុំគ្នា ហើយដំណើរខ្ញុំបន្តទៅទៀត គឺឆ្ពោះទៅអឺរ៉ុប ។ សំខាន់ដែលខ្ញុំមកលើកនេះ គឺសំដៅទៅអឺរ៉ុប ប៉ុន្តែយើងឈាងមកចូលសហរដ្ឋអាមេរិកនេះតែដប់ថ្ងៃទេ ។ បេសកកម្មខ្ញុំទៅអឺរ៉ុបនេះ ថ្ងៃទី៣១ ខ្ញុំទៅដល់ប្រទេសបារាំង, ហើយថ្ងៃទី២ ខ្ញុំទៅប្រទេសអ៊ីតាលី, ថ្ងៃទី៥ ទៅអូទ្រីស ហើយបន្ទាប់ខ្ញុំទៅ បែលហ្ស៊ិក, ហូឡង់, ដាណឺម៉ាក់ ហើយនៅថ្ងៃទី២១ ខែមេសា ខ្ញុំត្រឡប់ទៅកាន់ប្រទេសកម្ពុជាវិញ ។

អ៊ឹម លឿម : បាទអរគុណឯកឧត្តម ខ្ញុំសូមជម្រាបសួរឯកឧត្តមថា តើបច្ចុប្បន្នគណបក្សសិទ្ធិមនុស្សមានការវិវឌ្ឍន៍ដល់កំរិតណា ឬមួយមានការថមថយនៅចំនួនអ្នកគាំទ្រទាំងក្រៅ និងក្នុងប្រទេសបែបណាដែរបាទ ?

កឹម សុខា : យើងមើលតាមរូបភាពពីរ ដែលខ្ញុំអាចបញ្ជាក់ថា មានសន្ទុះប៉ុណ្ណា ដោយទីមួយតាមរយៈការស្ទង់មតិរបស់អង្គការ IRI ជាអង្គការអាមេរិកាំងមួយ ដែលមានទីតាំងនៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី ហើយបានធ្វើការស្ទង់មតិនៅប្រទេសកម្ពុជា គេរកឃើញថា កាលពីពេលទើបនឹងបង្កើតបាន១ឆ្នាំ បានទទួលអ្នកបោះឆ្នោតឱ្យជិត៤០ម៉ឺនសម្លេង បើគិតជាភាគរយបាន ៦,៧ ភាគរយ បើគិតជាកៅអីបាន ៣ កៅអី ។ ប៉ុន្តែក្រោយការបោះឆ្នោតមួយឆ្នាំ គេស្ទង់មតិនៅខែ ៨ ឆ្នាំ២០០៩ នេះ គេឃើញកំណើននៃការកើនអ្នកគាំទ្រគណបក្សសិទ្ធិមនុស្សឡើងជាងទ្វេរដង ឡើងពី ៦,៧ រហូតដល់ ១៤ ភាគរយ គឺឡើងជាពីរដង មានន័យថា ៤០ម៉ឺន ឡើងជាង ៨០ម៉ឺន គឺជិតមួយលាននាក់ហើយ ។ ទី២ គឺតាមជាក់ស្តែង, ការជាក់ស្តែងគឺបន្ទាប់ពីខ្ញុំត្រឡប់ពីសហរដ្ឋអាមេរិកវិញ ខ្ញុំបានទទួលការស្នើសុំពីប្រជាពលរដ្ឋនៅតាមខេត្តមួយចំនួន បានផ្ញើតមេដៃបានឱ្យខ្ញុំចុះទៅតាមបណ្តាឃុំ ដោយមានការចូលរួមថ្មី ជាពិសេស អ្នកដែលធ្លាប់បោះឆ្នោតឱ្យហ្វ៊ុនស៊ិនប៉ិច, នរោត្តម រណឫទ្ធិ គឺភាគច្រើនសុំមកចូលរួមជាមួយគណបក្សសិទ្ធិមនុស្ស ដោយអស់សង្ឃឹមជាមួយគណបក្សទាំងពីរហ្នឹង ។


លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស

ហើយទី២ខាងគណបក្ស សម រង្ស៊ី ដោយឃើញថា លោក សម រង្ស៊ី មិនឆ្លើយតបពីរឿងការរួបរួមនេះ ធ្វើឱ្យអ្នកគាំទ្រលោក សម រង្ស៊ី នៅតាមមូលដ្ឋាន បានសម្រេចចិត្តមួយចំនួនចូលរួមជាមួយគណបក្សសិទ្ធិមនុស្ស ។ ទីបី គឺយើងមានការភ្ញាក់ផ្អើលនៅពេលខ្ញុំត្រឡប់ទៅវិញ នេះមានទាំងអ្នកគាំទ្រគណបក្សប្រជាជននៅតាមមូលដ្ឋានខ្លះ ដែលធ្លាប់បោះឆ្នោតឱ្យបក្សប្រជាជនក៏សម្រេចចិត្តចូលជាមួយគណបក្សសិទ្ធិមនុស្ស ។ ឧទាហរណ៍ : ដូចជា ខេត្តកំពត បងប្អូនយើងមានសុំឱ្យខ្ញុំចុះទៅ, មួយភូមិមានទាំងប្រធានភូមិទៅ គឺបានទទួលការស្វាគមន៍ខ្ញុំ ពេលខ្ញុំចុះទៅហ្នឹង, អញ្ចឹងឃើញសន្ទុះនេះ ខ្ញុំមើលទាំងការស្ទង់មតិក៏ឃើញថាកើន, ការជាក់ស្តែងឃើញកើន ។

អ៊ឹម លឿម : ក្នុងនាមឯកឧត្តមជាប្រធានគណ-បក្សដ៏ទាស់មួយដ៏ល្បីល្បាញនៅក្នុងប្រទេសកម្ពុជា តើឯកឧត្តមអាចជម្រាបបានទេថា តើក្រោមការដឹកនាំប្រទេសជាតិនាបច្ចុប្បន្នរបស់លោក ហ៊ុន សែន ធ្វើឱ្យប្រទេសជាតិរីកចម្រើនដល់កម្រិតណា ឬមួយថមថយយ៉ាងណាដែរបាទ ?

កឹម សុខា : បើប្រៀបធៀបជាមួយរបប ប៉ុល ពត គឺគ្រាន់បើជាង ប៉ុល ពត អាហ្នឹងវាជាក់ស្តែង ។ តែបើប្រៀបធៀបជាមួយប្រទេសដែលគេគោរពទ្រឹស្តីលទ្ធិ-ប្រជាធិបតេយ្យ ឬក៏ប្រទេសមួយដែលគេមានការស្រឡាញ់ជាតិ, ស្រឡាញ់ប្រជាពលរដ្ឋ, ស្មោះត្រង់នឹងជាតិ យើងឃើញថា នៅទន់ខ្សោយណាស់ ។ បើប្រៀបធៀបនូវរបស់ដែលបាន គឺរបស់ដែលបាត់មានច្រើនជាងបាន ខ្ញុំឧទាហរណ៍ដូចជា ព្រៃឈើ, ដីធ្លី, ទ្រព្យសម្បត្តិជាតិ, បឹងបួរ, រ៉ែ គឺបាត់បង់ច្រើនណាស់ ។ អាហ្នឹងគឺរបស់ដែលបាត់ គឺឃើញច្រើនណាស់ ប៉ុន្តែរបស់ដែលបាន គឺឃើញមានដូចជា ផ្លូវ ថ្នល់ មានពេទ្យ មានសាលា ប៉ុន្តែយើងឃើញមានជំនួយបរទេសច្រើនរាប់ពាន់លានដុល្លារក្នុងមួយឆ្នាំៗ ប៉ុន្តែយើងឃើញកំណើននៃការអភិវឌ្ឍន៍វាតិច, ហើយអភិវឌ្ឍន៍មួយចំណែកទៀតនោះ គឺទៅតាមអ្នកវិនិយោគទុន, វាជាការអភិវឌ្ឍន៍មួយលើទឹកភ្នែករាស្ត្រ គឺយកដីធ្លីប្រជារាស្ត្រមកឱ្យក្រុមហ៊ុន, យកមកឱ្យអ្នកមាន ហើយមិនថែមទាំងឱ្យក្រុមហ៊ុន និងអ្នកមានប៉ុណ្ណោះទេ គឺថែមទាំងឱ្យទៅបរទេសទៀត ។ គឺដូចពេលថ្មីៗនេះ ឱ្យទៅយួន ១០ម៉ឺនហិចតា ដាំកៅស៊ូនៅតាមជួរព្រំដែនតាំងពីខេត្តកំពង់ចាមនៅស្រុកមេមត់ រហូតដល់ខេត្តក្រចេះ នៅស្រុកស្នួល ខេត្តមណ្ឌលគិរី នៅស្រុកកែវសីមា រហូតដល់ស្ទឹងត្រែង, រតនៈគិរី និងរហូតដល់ខេត្តកំពង់ធំ ដែលជាតំបន់កណ្តាលនៃប្រទេសទៀត ។

(តទៅលេខក្រោយ)

# សម រង្ស៊ី ស្វែងរកឃើញឯកសារពិតពីរឿងព្រំដែនខ្មែរ_យួន ?

**តទៅនេះ គឺជាកិច្ចសម្ភាសន៍រវាងកាសែតខ្មែរប៉ុស្តិ៍ និងលោក សម រង្ស៊ី ដែលមានខ្លឹមសារដូចតទៅ :**

**មាជ សុវណ្ណារ៉ា :** លោកប្រធានគណបក្ស សម រង្ស៊ី កាលពីថ្ងៃទី13 ខែមីនា ឆ្នាំ2010 នៅប្រទេសបារាំង គឺបងប្អូនខ្មែរនៅប្រទេសបារាំងបានមកគ្រប់ពីបណ្តាក្រុងនានា ការជួបជុំគ្នាក្នុងកិច្ចពិភាក្សាទាក់ទងទៅនឹងប្រធានបទស្វែងយល់ពីការពិតដើម្បីការពារបូរណភាពទឹកដី ។ ហើយនៅក្នុងឱកាសនោះដែរក្នុងចំណោមមនុស្សរាប់រយនាក់លោកប្រធានបានប្រាប់ទៅបងប្អូនខ្មែរ នៅទីនោះថា លោកប្រធាននឹងបង្ហាញឯកសារផែនទីពិតមួយដើម្បីលាតត្រដាងថា តើប្រទេសកម្ពុជាបាត់បង់ទឹកដី ឬក៏មិនបាត់បង់ ។ តើរដ្ឋាភិបាលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅជាអ្នកបំភ័ន្តភ្នែកអន្តរជាតិ ភ្នែកមតិរបស់ប្រជាជនខ្មែរ ថាមិនបាត់បង់ទឹកដីទេ ។ តើបញ្ហានេះលោកអាចលើកបង្ហាញឯកសារអ្វីដែលលោកនឹងលាតត្រដាងឱ្យឃើញការពិតនោះបាទ?

**សម រង្ស៊ី :** ភស្តុតាងហ្នឹង គឺមានផែនទីមួយឈុត ដែលគេតម្កល់ទុកនៅប្រទេសបារាំង ពីព្រោះថា ប្រទេសបារាំងហ្នឹងហើយដែលជាអ្នករៀបចំផែនទីឱ្យយើងមុនគេបង្អស់ប្រមាណ 100ឆ្នាំមកហើយ ពេលដែលបារាំងធ្វើអាណានិគមនិយមនៅប្រទេសកម្ពុជា គេមានក្រុមបច្ចេកទេសគេដែលបានគូស និងវាស់វែងព្រំដែនរវាងប្រទេសកម្ពុជា ហើយពេលនោះជាមួយនឹង ឥណ្ឌូចិន ក្នុងគម្រោងក្នុងក្របខណ្ឌឥណ្ឌូចិន គឺជាមួយកូសាំងស៊ីន ។ ហើយផែនទីគេបានរៀបចំបណ្តើរៗកាន់តែច្បាស់ឡើងៗ ហើយថ្មីៗនេះគេបានបញ្ចូលបច្ចេកទេសទំនើបក្នុងការវាស់វែងក្នុងការបញ្ជាក់ព្រំដែនឱ្យកាន់តែច្បាស់លាស់ថែមទៀតបាទ ! ។

**មាជ សុវណ្ណារ៉ា :** លោកប្រធានដែលលោកអះអាងនោះពីឆ្នាំណាដែរបាទ ! ?

**សម រង្ស៊ី :** ផែនទីហ្នឹងមុនគេបង្អស់មានតាំងពីឆ្នាំ1920 ឥឡូវឆ្នាំ2010 គឺមានរយៈពេល90ឆ្នាំហើយ ។ រួចបណ្តើរៗរហូតដល់ប្រហែលជាឆ្នាំ1950 ប្លាយ ក៏គេមានផែនទីដែលគេធ្វើបច្ចុប្បន្នភាពបន្ថែមទៀត ។ បន្តមកទៀតក៏មានផែនទីអាមេរិកាំងបានធ្វើពេលមានសង្គ្រាមនៅប្រទេសវៀតណាម ។ ហើយពេលថ្មីៗនេះថែមទៀតគេមានបច្ចេកទេសថ្មី ដែលផ្អែកលើផ្កាយរណបផ្អែកលើប្រព័ន្ធកុំព្យូទ័រ ហើយគេអាចឆ្លុះវាស់វែងកាន់តែច្បាស់ថែមទៀតថា ព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាមនៅតំបន់នីមួយៗ តើមានរូបរាងយ៉ាងម៉េច ? ហើយកន្លែងដែលខ្ញុំទៅដកបង្គោលអ្វីដែលគេហៅថា បង្គោលព្រំដែនកន្លែង នោះមិនមែនជាព្រំដែនទេ តែវាស្ថិតនៅលើទឹកដីរបស់ប្រទេសកម្ពុជា ។ ហើយបង្គោលនោះដូចខ្ញុំនិយាយពីមុន គឺមិនមែនជាបង្គោលព្រំដែនទេ តែជាបង្គោលឈ្លានពាន ហើយឥឡូវនេះខ្ញុំត្រូវតែបញ្ជាក់ជូនប្រជារាស្ត្រខ្មែរជ្រាបឱ្យបានច្បាស់ថា បង្គោលនោះជាបង្គោលឈ្លានពានមែន ពីព្រោះស្ថិតនៅក្នុងទឹកដីប្រទេសកម្ពុជា ។ អ៊ីចឹងអ្វីដែលខ្ញុំអះអាងនេះ គឺឈរលើការពិត ហើយការពិតនោះខ្ញុំ នឹងលាតត្រដាងបញ្ចេញឱ្យសាធារណៈមតិបានដឹងឮទាំងអស់គ្នា ។




**មាជ សុវណ្ណារ៉ា :** ទាក់ទងទៅនឹងបញ្ហាបូរណភាពដែនដីនេះដែរ តើការបង្ហាញឯកសារនេះ ដើម្បីផលប្រយោជន៍អ្វីដែរ ? ហើយផែនទីឯកសារហ្នឹងសំអាងទៅលើអ្វីដែលលោកប្រធានបាទ ! ? ។

**សម រង្ស៊ី :** អ្វីដែលគណបក្ស សម រង្ស៊ី ធ្វើ គឺដើម្បីការពារផលប្រយោជន៍ជាតិ ។ ទឹកដីដែលខ្ញុំកំពុងជួយការពារហ្នឹងមិនជាទឹកដីរបស់ខ្ញុំ សម រង្ស៊ី មិនមែនជាទឹកដីរបស់គណបក្ស សម រង្ស៊ី ទេ ជាទឹកដីរបស់ខ្មែរយើងទាំងអស់គ្នា ។ ដូច្នេះយើងត្រូវតែខិតខំអស់ពីសមត្ថភាពអស់ពីលទ្ធភាដែលខ្ញុំកំពុងធ្វើនៅប្រទេសបារាំងនេះ គឺជាឱកាសប្រវត្តិសាស្ត្រមួយ ដើម្បីការពារទឹកដីនៃជនជាតិខ្មែរយើងទាំងអស់គ្នា ។ ហ្នឹងហើយផលប្រយោជន៍សម្រាប់ប្រទេសជាតិដែលយើងទាំងអស់ត្រូវតែរួបរួមគ្នាដើម្បីលាតត្រដាងការពិតមិនអាចមានយុត្តិធម៌បានទេ បើគ្មានការពិត ។ ការពិត គឺជាមូលដ្ឋាននៃយុត្តិធម៌ ដើម្បីស្វែងរកយុត្តិធម៌ជូនទាំងប្រទេសជាតិយើង ជូនទាំងកសិករខ្មែរ ដែលពួកគាត់បាត់បង់ដីធ្លី ដីស្រែរបស់គាត់ដោយបរទេសឈ្លានពានលេបត្របាក់យកដីស្រែគាត់ ហើយអាជ្ញាធរខ្មែរនៅប្រទេសកម្ពុជា ចាប់ពួកគាត់ដាក់គុកទៀត ។ ដូច្នេះខ្ញុំ ត្រូវតែខិតខំស្វែងរកយុត្តិធម៌ជូនគាត់ ។ ខ្ញុំជឿថា ពេលដែលខ្ញុំលាតត្រដាងផែនទីនេះ ភស្តុតាងនេះ ឯកសារនេះបញ្ជាក់យ៉ាងច្បាស់ថា ទឹកដីនេះជាទឹកដីរបស់ខ្មែរ ទី1 កសិករខ្មែរដែលគេបានចាប់ដាក់គុកនោះត្រូវតែដោះលែងវិញ ហើយគេហ្នឹងប្រគល់សងជូនពួកគាត់វិញ ហ្នឹងរឿងដែលជនជាតិខ្មែរយើងរស់នៅតាមព្រំប្រទល់ដែន ។ តែចំពោះប្រទេសកម្ពុជាយើងទាំងមូលប្រទេសយើងហ្នឹងទទួលមកវិញនូវផ្ទៃដីដែលបរទេសឈ្លានពានបានលេបត្របាក់ ហើយអាជ្ញាធរ រដ្ឋាភិបាលសព្វថ្ងៃមិនអាចប្រកែកបាន ។ ពេលហ្នឹងត្រូវឱ្យមានជំហរឱ្យម៉ឺងម៉ាត់ ពីព្រោះបើខ្ញុំបង្ហាញភស្តុតាងប៉ុណ្ណឹងហើយ មិនយកភស្តុតាងហ្នឹងទៅតាមឱ្យយួនដកថយ នៅតែបណ្តោយឱ្យយួនគ្រប់គ្រងទឹកដីប្រទេសកម្ពុជាបែបហ្នឹងទៀត គឺប្រជារាស្ត្រទាំងមូលនឹងឃើញយ៉ាងច្បាស់ថា រដ្ឋាភិបាលសព្វថ្ងៃមិនមែន បម្រើផលប្រយោជន៍ឱ្យខ្មែរទេ គឺបម្រើផលប្រយោជន៍ឱ្យបរទេសឯណោះទេ។ បាទ ! គឺបានមកពីវិទ្យាស្ថានជាតិផ្អែកភូមិសាស្ត្រនៅប្រទេសបារាំង បានមកពីស្ថាបន័បច្ចេកទេសស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្រនៅប្រទេសបារាំងសុទ្ធតែជាស្ថាប័នជាតិ មានគ្រូបង្រៀន នាយកស្រាវជ្រាវដែលមានសាស្ត្រាចារ្យនៅមហាវិទ្យាល័យនានានៅប្រទេសបារាំង មិនមែនតែនៅប្រទេសបារាំងទេ គឺមាននៅប្រទេសស្វីសទៀតក៏បានចូលរួមក្នុងហ្នឹងដែរ ។ (តទៅលេខក្រោយ)

# រស់ យឹន មិនថយក្រោយ



*•••គណបក្សខ្មែរសាធារណរដ្ឋតំណាងដោយកូនលោកអតីតប្រធានាធិបតី លន់ នល់ បានចូលរួមក្នុងការបោះឆ្នោតឆ្នាំ ២០០៨ តែពុំបានទទួលអាសនៈនៅសភាណាមួយទេ។ តើគណបក្សមួយនេះ មានដំណើរការណ៍យ៉ាងណាហើយ សូមអានបទសម្ភាសន៍របស់ខ្មែរប៉ុស្តិ៍ដូចតទៅ :*

ខ្មែរប៉ុស្តិ៍ : ជំរាបសួរលោក រស់ យឹន បងប្អូនខ្មែរនៅសហរដ្ឋអាមេរិក បានដឹងថា លោកជាអគ្គលេខាហគណបក្សខ្មែរសាធារណរដ្ឋ ដែលកំពុងបំពេញបេសកកម្មលើទឹកដីអាមេរិក តើលោកបានជួបពិភាក្សាការងារជាមួយលោក លន់ ឬទ្ធិ ដែលជាប្រធានគណបក្ស បានលទ្ធផលដូចម្តេចខ្លះ ?

រស់ យឹន : បាទ ជាការពិតណាស់លោក ! ខ្ញុំបានជួបនឹងលោកប្រធាន លន់ ឬទ្ធិ ហើយ ។ រីឯលទ្ធផលជាវិជ្ជមាន ឬអវិជ្ជមាន ខ្ញុំមិនអាចជំរាប់មុនបានទេ ។

ខ្មែរប៉ុស្តិ៍ : ព្រោះហេតុអ្វី ?

រស់ យឹន : ពីព្រោះយើងខ្ញុំកំពុងស្វែងរកសម្បត្តិមនសិការជាតិពីសំណាក់បងប្អូនខ្មែរ ដែលនៅក្រៅប្រទេស ។ គណបក្សខ្មែរសាធារណរដ្ឋ ចង់បានទី១នូវឧត្តមគតិខ្មែរ ដែលយល់ដឹងថា មាតុភូមិយើងកំពុងមានគ្រោះថ្នាក់ ។

ខ្មែរប៉ុស្តិ៍ : ចុះការបោះឆ្នោតក្នុងអាណត្តិទីមួយនៅឆ្នាំ ២០០៨ បានលទ្ធផលយ៉ាងណាដែរ ?

រស់ យឹន : បាទ ! ជំរាបតាមត្រង់ យើងបានជើងកៅអីមួយ បើគិតជាសម្លេងមធ្យមពី ៤ម៉ឺនឡើងទៅ ព្រោះយើងទទួលបានសន្លឹកឆ្នោតតែជាង ១ម៉ឺនប៉ុណ្ណោះ ក្នុងខេត្ត ៩ ដែលយើងមានសំណាងបានឈរឈ្មោះលេខរៀងទី៦ បណ្តាគណបក្សចំនួន ១១ ដែលឡើងប្រកួតលើសៃវៀនសាធារណៈ ។

ខ្មែរប៉ុស្តិ៍ : ចុះក្រោយពីបរាជ័យដ៏ធ្ងន់នោះមក តើសព្វថ្ងៃក្រុមការងាររបស់លោកមានចិត្តកសាងបក្សទៀតឬទេ ?

រស់ យឹន : បាទ ! បាទ ! បាទ ! សូមអរគុណសុំជំរាបថា គណបក្សខ្មែរសាធារណរដ្ឋ មានឈ្មោះ ធំ ទំហំតូច, ចិត្តខ្លាំងមិនដល់, មាត់ធំជាងក្បាល, លីពូថៅដើរកាត់ផ្សា, ប៉ុន្តែឥឡូវនេះ មានបទពិសោធន៍គួរសម បានកសាងបក្សពី ៩ខេត្ត ដល់ ២៤ខេត្តក្រុងដែរហើយ ។

ខ្មែរប៉ុស្តិ៍ : លោក រស់ យឹន យ៉ាងម៉េចទៅ ដែលហៅថា មាឌធំ ទំហំតូច ?

រស់ យឹន : បាទ ! ព្រោះគណបក្សនេះ មានឈ្មោះប្រហាក់ប្រហែលរបបសាធារណរដ្ឋដ៏ធំមហិមាសម័យ ១៨ មីនា ១៩៧០ ។ រីឯទំហំតូច មានន័យថាលោកមេបក្ស លន់ ឬទ្ធិ ជាកូនលោកសេនាប្រមុខ លន់ នល់ ខ្វះបទពិសោធន៍កិច្ចការនយោបាយ ហើយនិយាយភាសាខ្មែរមិនទាន់ច្បាស់នៅឡើយផង ។

ខ្មែរប៉ុស្តិ៍ : ចុះពាក្យថា មាត់ធំជាងក្បាល, ចិត្តខ្លាំងមិនដល់ ?

រស់ យឹន : បាទ ! ព្រោះយើងបានតាំងចិត្តជំនះឧបសគ្គគ្រប់យ៉ាង ដើម្បីធ្វើបក្សមួយឈ្មោះ ខ្មែរសាធារណរដ្ឋ អាស្រ័យធម្មនុញ្ញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ កម្លាំងមិនដល់ គឺខ្វះ (ទ ៣) ចំណែកឯមាត់ធំជាងក្បាល គឺពូកែតែស្រែក តែពាក្យខ្លះខ្វះយោបល់ ។

ខ្មែរប៉ុស្តិ៍ : តើស្អីទៅ ទ ៣ លោកអាចពន្យល់អ្នកអានបានឬទេ ?

រស់ យឹន : បាទលោក ! កិច្ចការកសាងបក្សនយោបាយសំរាប់ដឹកនាំជាតិ ត្រូវប្រកបដោយ ទ៣ ទទី១ គឺទុន, ទទី២ ទ័ព, ទទី៣ ទូត ប៉ុន្តែរបបប្រជាធិបតេយ្យសេរីពហុបក្ស មិនអនុញ្ញាត្តិឱ្យបង្កើតទ័ពទេ ដូច្នេះនៅតែការស្វែងរក ដើមទុន និងចេះធ្វើការទូត ដើម្បីសុំការគាំទ្រពីសំណាក់ប្រទេសលោកសេរី។

ខ្មែរប៉ុស្តិ៍ : ចុះស្អីទៅហៅថា លីពូថៅកាត់ផ្សារ?

រស់ យឹន : បាទ ! ពាក្យនេះជាពាក្យចាស់បុរាណសំរាប់ប្រដូចមនុស្សណា ដែលមិនចេះច្បាប់, មិនស្គាល់ភូមិសាស្ត្រ ក៏ដូចជាកីឡាករប្រថុយប្រថាន តតតិតដល់កីឡាករជើងចាស់ជើងថ្មីទេ... ។

ខ្មែរប៉ុស្តិ៍ : ចុងបញ្ចប់ តើលោកអ្នកមានសង្ឃឹមថាមានជ័យជំនះនៅពេលបោះឆ្នោតក្រោយៗទៀតទេ?

រស់ យឹន : សេចក្តីសង្ឃឹមដ៏ពិតប្រាកដរបស់យើងខ្ញុំ គឺការធ្វើយ៉ាងណាឱ្យមាតុភូមិខ្មែរ គេចផុតពីការហ៊ុំព័ទ្ធនៃយុទ្ធសាស្ត្រកុម្មុយនិស្ត បាទ ! ក្រៅពីនោះមិនបាច Take care ទេបាទ !!!

ខ្មែរប៉ុស្តិ៍ : សូមអរគុណលោក រស់ យឹន : សង្ឃឹមថានឹងបានជួបលោកសារជាថ្មី ។

រស់ យឹន : បាទ ! សូមជំរាបលា... ៕

## សមាគមព្រឹទ្ធាចារ្យខ្មែរ_អាមេរិកាំង
## សេចក្តីអញ្ជើញ

**កម្មវត្ថុ :** ការបោះឆ្នោតជ្រើសរើសប្រធានរបស់សមាគមព្រឹទ្ធាចារ្យខ្មែរ-អាមេរិកាំង ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១០

**របៀបវារៈ :**

១-សេចក្តីរាយការណ៍របស់ប្រធានចាស់

២-ការរំលាយគណៈកម្មាធិការចាស់

៣-ការរៀបចំធ្វើការបោះឆ្នោត

ខ្ញុំបាទ អ៊ូ កៅ អ្នកជួយសំរួលការក្នុងការបោះឆ្នោតជ្រើសរើសប្រធានរបស់សមាគមព្រឹទ្ធាចារ្យខ្មែរ-អាមេរិកាំង សូមអញ្ជើញអស់លោក លោកស្រី ដែលជាសមាជិក សមាជិកា មកចូលរួមឱ្យបានកុះករ ដើម្បីបោះឆ្នោតជ្រើសរើសប្រធានសំរាប់អាណត្តិថ្មី ។

ការបោះឆ្នោតនិងព្រឹត្តទៅនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១០ នៅទីស្នាក់ការរបស់សមាគមព្រឹទ្ធាចារ្យខ្មែរ-អាមេរិកាំង ដែលមានអស័យដ្ឋាន : 1622 S.7th Street Philadelphia, PA 19148 នៅវេលាម៉ោង ១០ព្រឹក ។

បើអស់លោក លោកស្រី ដែលមិនទាន់បានចូលជាសមាជិកនៅឡើយ សូមប្រញ៉ាប់ប្រញ៉ាល់ទាក់ទង និងលោក Kau Our (215) 227-5893, Chin Wutha (267) 736-0445, Va Samon (215) 551-0553, Mao Man (215) 336-3039, Thim Kouch (215) 776-4174 ដើម្បីចុះឈ្មោះឱ្យបានមុនថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១០ ខាងមុខនេះកុំបីខាន ។

សូមអរគុណ !

អ៊ូ កៅ

គណៈកម្មាធិការបោះឆ្នោត ។


ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ-អង្គរ

Angkor International Travel Agency




ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ

សេវាលិខិតឆ្លងដែន

សេវាអន្តោប្រវេសន៍

កក់សណ្ឋាគារ ឬជួលឡាន

USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO

angkortravelphilly@yahoo.com

Cambodia Office: Victory Travel (Skin Belle)
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.

SERVING SINGAPOR, EVA AIR, KOREAN AIRLINES, MALAYSIA etc...

New World Travel II

ញូវេលត្រាវែលធូ

Specialized in Selling Flight Tickets
For National and International

ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថេ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។

Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations

600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

# A.B.C MONEY TRANSACTION, INC

# $ ក្រុមហ៊ុនផ្ញើប្រាក់ A.B.C



## តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ

| | | ភ្នំពេញ | តាមខេត្ត |
|---|---|---|---|
| ផ្ញើ $100 | យកកម្រៃ | $4.50 | $5.50 |
| $200 | យកកម្រៃ | $9.00 | $11.00 |
| $300 | យកកម្រៃ | $13.50 | $16.50 |
| $500 | យកកម្រៃ | $16.00 | $17.00 |
| $1000 | យកកម្រៃ | $25.00 | $26.00 |
| $1500 | យកកម្រៃ | $35.00 | $36.00 |
| $2000 | យកកម្រៃ | $42.00 | $43.00 |
| $2200 | យកកម្រៃ | $46.00 | $47.00 |

សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

### នៅរដ្ឋ VIRGINIA សូមទាក់ទង

**ABC MONEY TRANSATION ,INC.**

**8 locations to serve you in Virginia**

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

**ARIZONA**

◆4215 N 19th Ave. . Tel : 602.266.6744

**GEOERGIA**

◆ 4897 Buford Hwy. Ste. 202. Tel: 770.457.7888

**ILLINOIS**

◆4871 N. Broadway . Tel :773.989.7332

**MASSACHUSETTE**

◆ 996 Dorchester Ave. Tel:617.825.9380

◆ 1365-1377 Dorchester Ave. -Ste.4,Froor 1 .Tel : 617.265.4600

**MINNESOTA**

◆ 2718 Nicollet Ave . S.- Ste. 102 B

◆ Tel : 612.871.4731

◆ 6350 Brooklyn Blvd . Tel : 763.503.3947

**NORTH CAROLINA**

◆ 3000 Central Ave. Ste . #9 . Tel : 704-532-4420

**OREGON**

◆6908 N.E. Sandy Blvd . Tel : 503.281.8088

**PHILADFELPHIA**

◆5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794

◆571 Adams Ave . Ave.#4 . Tel : 215.342.6623

**TEXAS**

◆1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461

◆2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817

◆5302 E . Belknap St.- Ste.D6 . Tel : 817.831.4836

◆3538 W . Walnut St. Tel : 972.272.2253

◆11205 Bellaire Blvd . Tel : 281.561.6600

◆10909 Scarsdale Blvd . Tel : 281.481.2700

◆13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

**WASHINTON STATE**

◆766 S.38th St,. Tel : 253.475.2847

◆3818 S.Graham St.-Ste. C Tel : 206.721.2070

Office : 714-590-8740 Fax : 714-590-8776
Cell: 714-603-3509 Toll Free : 1-877-939-0110

## ក្រុមហ៊ុនទទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

### ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្ទាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ ( NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS ) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័ត៌មានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងថ្មីៗសំរួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសៅរ៍-អាទិត្យ ទី៣-៤ ខែមេសា ឆ្នាំ២០១០

# US Suspende Military Shipment over Deportations of Uighurs

By Mark Worley and Phann Ana
THE CAMBODIA DAILY

The US has suspended the delivery of 200 military trucks to Cambodia in retaliation for the government's decision to deport 20 Uighur asylum seekers back to China in December.

At a press briefing in Washington on Thursday, US State Department spokesman Philip Crowley said Cambodian government officials were notified on March 19 that the delivery of military vehicles under the excess defense article program had been halted.

"This [program] is something that I think is important to Cambodia and obviously, as we said previously, there would be consequences for their failure to live up to the international obligations," Mr Crowley told reporters in Washington, according to a transcript on the State Department's website.

Cambodia earned the wrath of the US, the UN and rights groups in December when it delivered 20 Uighur asylum seekers into Chinese custody without allowing the UN refugee agency to complete its assessment of their refugee status.

At the time, Interior Ministry spokesman Lt General Khieu Sopheak said the government sent the asylum seekers back to China after an investigation revealed that they were criminals connected to a terrorist group in China.

Information Minister and government spokesman Khieu Kanharith said yesterday that blaming the government for the Uighur deportations was "crazy."

"The shipment [of trucks] belongs to the US government, and they have the right to decide if they send it or not," Mr Kanharith said.

"But blaming Cambodia for the Uighurs is crazy, as for one month the US-backed authorities could not determine their refugee status. The Chinese government made a request to us based on the rule of law in their country. How could we refuse?"

US Embassy spokesman John Johnson said yesterday that the suspension of the military shipment would remain in effect for "an undefined period," but added that no further sanctions were being considered.

"We were deeply disturbed that the Cambodian government, at China's request and in apparent violation of its international obligations, forcibly removed 20 Uighur asylum seekers back to China in December without the benefit of a credible process for determining refugee status," Mr Johnson said in an e-mail yesterday.

"The suspension will affect some 200 vehicles and trailers that had been identified for shipment. We have thoroughly reviewed this issue and are not considering additional actions."

CPP lawmaker Cheam Yeap yesterday asked the US government to reconsider the military aid suspension, adding that the US has never "fully supported" Cambodia.

"[The US] has given lots of aid to other countries, while Cambodia has received very little," Mr Yeap said. "Cambodian citizens are quite disappointed that the US government has never fully helped Cambodia."

"I would like to inform the US Embassy and US President Barack Obama that Cambodia's act [of returning the Uighurs to China] was merely made according to the legal procedure of Cambodian law towards Chinese nationals who had illegally entered Cambodia."

Ministry of Defense spokesman Chhum Sucheat said the US decision to suspend the shipment would not cause a rift between the two countries' militaries.

"We do not comment on political policy, [but] we are not upset or angry," Mr Sucheat said, adding that the trucks were intended to be used for transporting military units throughout Cambodia's provinces.

Adhoc President Thun Saray said he was pleased to see the US link assistance to Cambodia with human rights obligations, but questioned why such linkages were not being applied to other human rights issues.

"This kind of decision could make the government more cautious about deporting people seeking refugee status in the future," Mr Saray said.

"But 20 Uighurs were affected by this deportation—what about the thousands of Cambodians who are having their land grabbed from them illegally? What is the difference?"

Qian Hai, second secretary and spokesman for the Chinese Embassy in Phnom Penh, said yesterday he had no information about the current status of the 20 deported Uighurs.

# អាមេរិកផ្អាកជំនួយយោធាដោយសារការនិរទេសជនជាតិវីហ្គួ

ដោយ : MARK WORLEY និង ផាន់ អាណា
THE CAMBODIA DAILY

សហរដ្ឋអាមេរិកបានផ្អាកការប្រគល់រថយន្តយោធាចំនួន២០០គ្រឿងដល់ប្រទេសកម្ពុជា ជាការតបទៅនឹងសេចក្តីសម្រេចរដ្ឋាភិបាល ក្នុងការនិរទេសក្រុមអ្នកស្វែងរកសិទ្ធិជ្រកកោន វីហ្គួ ២០ នាក់ ទៅប្រទេសចិនវិញ កាលពីខែធ្នូ ។

នៅសន្និសីទកាសែតមួយនៅទីក្រុងវ៉ាស៊ីនតោនកាលពីថ្ងៃព្រហស្បតិ៍ លោក ហ្វីលីព ក្រូលី អ្នកនាំពាក្យក្រសួងការបរទេសអាមេរិកបានមានប្រទេសសាសន៍ថា ក្រុមមន្ត្រីរដ្ឋាភិបាលកម្ពុជា ត្រូវបានជូនដំណឹងកាលពីថ្ងៃទី១៩ ខែមីនាថា ការប្រគល់រថយន្តយោធាក្រោមកម្មវិធីជំនួយផ្នែកការពារជាតិដ៏លើសលប់នេះត្រូវបានផ្អាកហើយ ។

យោងតាមសម្រង់អត្ថបទដែលមាននៅលើវេបសាយរបស់ក្រសួងការបរទេសអាមេរិក លោក ក្រូលី បានថ្លែងទៅកាន់ក្រុមអ្នកយកព័ត៌មាននៅក្នុងទីក្រុងវ៉ាស៊ីនតោនថា "កម្មវិធីនេះ គឺជាកម្មវិធីដែលខ្ញុំគិតថា សំខាន់ចំពោះប្រទេសកម្ពុជា ហើយជាក់ស្តែងដូចជាយើងបាននិយាយកាលពីថ្ងៃមុន និងមានផលលំបាកចំពោះការខកខានមិនបានអនុវត្តតាមកាតព្វកិច្ចអន្តរជាតិរបស់ពួកគេ" ។

ប្រទេសកម្ពុជា បានធ្វើឱ្យសហរដ្ឋអាមេរិក អង្គការសហប្រជាជាតិ និងអង្គការសិទ្ធិមនុស្សនានា មានការខឹងសម្បាកាលពីខែធ្នូ នៅពេលដែលខ្លួនបានបញ្ជូនក្រុមអ្នកស្វែងរកសិទ្ធជ្រកកោន វីហ្គួ ២០ នាក់ ទៅឱ្យក្រុមអាជ្ញាធរចិនដោយមិនបានអនុញ្ញាតឱ្យទីភ្នាក់ងារជនភៀសខ្លួនអង្គការសហប្រជាជាតិបញ្ចប់ការវាយតម្លៃរបស់ពួកគេពីឋានៈជាជនភៀសខ្លួនសិន ។

នៅពេលនោះ ឧត្តមសេនីយ៍ឯក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃបានមានប្រសាសន៍ថា រដ្ឋាភិបាលបានសំរេចបញ្ជូនក្រុមអ្នកស្វែងរកសិទ្ធជ្រកកោនទាំងនេះទៅប្រទេសវិញ បន្ទាប់ពីការស៊ើបអង្កេតបានបង្ហាញថាពួកគេ គឺជាឧក្រិដ្ឋជនដែលពាក់ព័ន្ធទៅនឹងក្រុមភេរវករក្នុងប្រទេសចិន ។

លោក ខៀវ កាញារីទ្ធ មន្ត្រីក្រសួងព័ត៌មាន និងអ្នកនាំពាក្យរដ្ឋាភិបាលបានមានប្រសាសន៍កាលពីម្សិលមិញថា ការបន្ទោសរដ្ឋាភិបាលកម្ពុជាចំពោះការនិរទេសជនជាតិវីហ្គួ "គឺជា រឿងឆ្កួត" ។

លោក ខៀវ កាញារីទ្ធ បានមានប្រសាសន៍ថា "ជំនួយរថយន្តទាំងនោះជាកម្មសិទ្ធិរបស់រដ្ឋាភិបាលអាមេរិក ហើយពួកគេមានសិទ្ធិសំរេចថា តើពួកគេបញ្ជូនវាមកឬក៏អត់" ។

"ប៉ុន្តែការបន្ទោសកម្ពុជារឿងជនជាតិ វីហ្គួ គឺជារឿងឆ្កួត ពីព្រោះអស់រយៈពេល១ខែក្រុមអាជ្ញាធរដែលគាំទ្រដោយអាមេរិកនេះ នៅតែមិនអាចសំរេចពីឋានៈជាជនភៀសខ្លួនរបស់ពួកគេបាន ។ រដ្ឋាភិបាលចិនបានធ្វើសំណើរមកពួកយើងផ្អែកតាមនីតិរដ្ឋនៅក្នុងប្រទេសរបស់ពួកគេ ។ តើយើងអាចបដិសេធយ៉ាងដូចម្តេចកើត? ។

លោក ចន ចនសុន អ្នកនាំពាក្យស្ថានទូតអាមេរិក បានមានប្រសាសន៍កាលពីម្សិលមិញថា ការផ្អាកជំនួយយោធានឹងនៅតែធ្វើក្នុង "រយៈមិនកំណត់" ប៉ុន្តែបានបន្ថែមថា មិនមានធ្វើការដាក់ទណ្ឌកម្មបន្ថែមកំពុងត្រូវបានពិចារណានៅឡើយ" ។

លោក ចន ចនសុន បានលើកឡើងតាមអ៊ីមែលកាលពីម្សិលមិញថា យើងមានការកាចិត្តយ៉ាងខ្លាំងដែលរដ្ឋាភិបាលកម្ពុជា តាមសំណើររបស់ចិន និងនៅក្នុងការរំលោភជាក់ស្តែងលើកាតព្វកិច្ចរបស់ខ្លួន បានបណ្តេញក្រុមស្វែងរកសិទ្ធិជ្រកកោន វីហ្គួ ២០ នាក់ ដោយបង្ខំទៅប្រទេសចិនវិញ កាលពីខែធ្នូ ដោយគ្មានឆ្លងកាត់ដំណើរការដែលគួរឱ្យជឿបានចំពោះការកំណត់ឋានៈជាជនភៀសខ្លួន" ។

"ការផ្អាកនេះនឹងប៉ះពាល់ការផ្តល់រថយន្តនឹងកន្ទុយសណ្តោងប្រហែល២០០គ្រឿងដែលត្រូវបានកំណត់ថាជាជំនួយ ។ យើងបានពិនិត្យយ៉ាងល្អិតល្អន់លើបញ្ហានេះ ហើយមិនកំពុងពិចារណាពីសកម្មភាពបន្ថែមទៀត " ។

លោក ជាម យៀប សមាជិកសភាគណបក្សប្រជាជនកម្ពុជា កាលពីម្សិលមិញបានស្នើររដ្ឋាភិបាលអាមេរិកឱ្យពិចារណាឡើងវិញ ពីការផ្អាកជំនួយយោធានេះ ដោយបន្ថែមថា សហរដ្ឋអាមេរិកមិនដែលបានគាំទ្រកម្ពុជាពេញលេញទេ ។

លោក ជាម យៀប បានមានប្រសាសន៍បន្តទៀតថា "សហរដ្ឋអាមេរិក បានផ្តល់ជំនួយយ៉ាងច្រើនដល់ប្រទេសដទៃ ចំណែកឯប្រទេសកម្ពុជា បានទទួលតិចតួចបំផុត ។ ពលរដ្ឋកម្ពុជាខកចិត្តយ៉ាងខ្លាំងដែលរដ្ឋាភិបាលអាមេរិកមិន ដែលបានជួយកម្ពុជា ដោយពេញលេញនោះ" ។

"ខ្ញុំសូមជម្រាបស្ថានទូតអាមេរិក និងលោក អូបាម៉ាថាសកម្មភាពរបស់កម្ពុជា (ទាក់ទិននឹងការបញ្ជូនជនជាតិវីហ្គួ ទៅប្រទេសចិនវិញ) គ្រាន់តែធ្វើឡើងតាមនិតិវិធីច្បាប់របស់កម្ពុជា ចំពោះជនជាតិចិនដែលបានចូលប្រទេសកម្ពុជា ដោយខុសច្បាប់ប៉ុណ្ណោះ" ។

លោក ឈុំ សុជាតិ អ្នកនាំពាក្យក្រសួងការពារជាតិ បានមានប្រសាសាន៍ថា សេចក្តីសំរេចរបស់រដ្ឋាភិបាលអាមេរិក ក្នុងការផ្អាកជំនួយរថយន្ត និងមិនបង្កឱ្យមានការប៉ះពាល់ដល់ទំនាក់ទំនងរវាងយោធារបស់ប្រទេសទាំងពីរនោះឡើយ ។

លោក ឈុំ សុជាតិ បានមានប្រសាសន៍បន្ត ទៀតថា "យើងមិនអត្ថាធិប្បាយអំពីកម្មវិធីនយោបាយទេ ប៉ុន្តែយើងមិនមានការតូចចិត្ត ឬក៏ខឹងសម្បាឡើយ " ដោយលោកបានបន្ថែមថា រថយន្តទាំងនេះមានបំណងប្រើប្រាស់ក្នុងការដឹកជញ្ជូនក្រុមយោធាទូទាំងខេត្តនានា នៅប្រទេសកម្ពុជា ។

លោក ធន សារាយ ប្រធានអង្គការសិទ្ធិមនុស្សអាដ-ហុកបានមានប្រសាសន៍ថា លោករីករាយដោយឃើញជំនួយរបស់អាមេរិកចំពោះប្រទេសកម្ពុជា ត្រូវបានភ្ជាប់ជាមួយនឹងកាតព្វកិច្ចសិទ្ធិមនុស្ស ប៉ុន្តែបានចោទសួរថាហេតុអ្វីបានការភ្ជាប់បែបនេះមិនត្រូវបានអនុវត្តចំពោះបញ្ហាសិទ្ធិមនុស្សដទៃទៀត ។

លោក ធន សារាយ បានមានប្រសាសន៍ថា "សេចក្តីសម្រេចបែបនេះ អាចធ្វើឱ្យរដ្ឋាភិបាលប្រុងប្រយ័ត្នជាងមុនអំពីការនិរទេសអ្នកស្វែងរកឋានជាជនភៀសខ្លួនក្នុងពេលអនាគត" ។

"ប៉ុន្តែជនជាតិ វីហ្គួ ២០ នាក់ ត្រូវបានប៉ះពាល់ដោយការនិរទេសនេះ ចុះចំណែកប្រជាជនកម្ពុជារាប់ពាន់នាក់ដែលត្រូវបានគេចាប់យកដីរបស់ខ្លួនដោយខុសច្បាប់នោះ? តើខុសគ្នាត្រង់ណា?"

លោក ឈាន ហៃ លេខាទី២និងជាអ្នកនាំពាក្យស្ថានទូតចិននៅក្នុងទីក្រុងភ្នំពេញបានមានប្រសាសន៍កាលពីម្សិលមិញថា លោកមិនមានព័ត៌មានអំពីស្ថានភាពបច្ចុប្បន្នរបស់ជនជាតិវីហ្គួ ទាំង២០នាក់ដែលត្រូវបាននិរទេសទេ ៕

ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)
Nam Vang Restaurant
571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market) **(215) 742-9488**
Open 7 days a week from 9 a.m. – 9 p.m.
បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច
១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្តាំង ឆារសាច់គោ
- មីកន្តាំងឆារគ្រឿងសមុទ្រ
- បាយឆារគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង
២_មុខជំនាញម្ហូបវៀតណាមល្បីឈ្មោះ ដូចជា:
- នំបញ្ចុកទឹកត្រីពិសេស
- នំប៉ុងបាតេ ឬសាច់គោអាំង
- ខគោ នំប៉ុង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់សេជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវ៉ូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ


ជាមួយ
តារាចម្រៀងខ្មែរពេញនិយម
Happy Khmer New Year!
កញ្ញា សុភី
លោក រ៉ម រឿន
ថ្ងៃសៅរ៍-អាទិត្យ ទី១៧-១៨
Saturday and Sunday, April 17-18, two popular Khmer Singers,
Mr. Rorm Roeurn and Ms. Sophy, will entertain all attendees.
Music performed by the two bands:
Khmer Reaksmey Kampucheakrom and Antry Meas Tontrey
Address: 2701 South 58th St, Philadelphia, PA 19143


HONG KONG
SUPERMARKET
FAMER´S BEST
LONGEVITY BRAND
$1.69/can
Café Du Monde
COFFEE AND CHICORY
$3.49 each
Newly Renovated.
Added new section .
Clean and Improved
management !
ទើបនឹងកែលំអរថ្មីឡើងវិញ
បន្ថែមផ្នែកលក់ថ្មីទៀត
ហាងស្អាត ហើយបង្កើន
គុណភាពគ្រប់គ្រង
Weekly Sale
លក់ចុះថ្លៃរៀងរាល់សប្តាហ៍
Vinacafe
$2.99/bag
Mazola
$7.99
$2.99
MAMA
$6.99/box
AROY-D
$1.29/can
$2.49/28oz
$2.49/bag
COCO RICO
2 for $3
$4.99 / lb
OPEN
7 DAY
8:00-9:00
571 ADAMS AVE.PHILADELPHIA,PA19120
Tel: 215-7281300 Fax: 215-728-1600
•ចំណាយ $140ដុល្លារ ទទួលបានអង្ករស្រូវស ២៥ ផោន
•ចំណាយ $100ដុល្លារ ទទួលបាននូវភេសជ្ជៈ ឬទឹកញ្ជប់មួយប្រអប់(តម្លៃ 8.99)
•ចំណាយ $25 ដុល្លារទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។

# សីហមុនី ឡើងសោយរាជ្យដោយករណីកិច្ច

**ដោយ : ដូមីនីក ឡាគ្លាដ កាសែត អ៊ិចប្រែស**

•••បណ្ឌិតសភាបារាំង L´Académie des inscriptions et Belles - lettres បានទទួលបដិសណ្ឋារកិច្ចដល់ព្រះរាជាខ្មែរ យ៉ាងអធិកអធម នៅទីក្រុងប៉ារីស កាលពីថ្ងៃសុក្រ ទី១២ ។

តទៅនេះ ជាការពិពណ៌នាអំពីបុរសម្នាក់ដែលមិនចង់សោយរាជ្យ :

ព្រះអង្គជាអ្នករាំម្នាក់ ជានាថករម្នាក់ ដែលមានលំនៅសង្កាត់លេខ ១៥ នៃទីក្រុងប៉ារីស ធ្វើដំណើរតែតាម "មេត្រូ" តែសព្វថ្ងៃនេះ ព្រះអង្គជាតំណរនៃវង្សក្សត្រាពីជំនាន់អង្គរមកហើយ ។ នរោត្តម សីហមុនី ដែលស្នងរាជ្យពីព្រះបិតា សីហនុ កាលពីខែ តុលា ឆ្នាំ ២004 និងត្រឡប់មកប្រទេសបារាំងវិញ នាសប្តាហ៍នេះ ជាបរទេសដែលរួមចំណែករបស់ L´Académie des inscriptions et Belles-lettres ។ ព្រះអង្គនឹងត្រូវទទួលបដិសណ្ឋារកិច្ចថ្ងៃទី១២ ខែមីនា នៅក្រោមដំបូលស្រួចនៃវិទ្យាស្ថានបារាំងដ៏ខ្ពង់ខ្ពស់ និងក្នុងឯកសណ្ឋានរបស់បណ្ឌិតសភា ។

វាសនាដ៏ចំឡែករបស់ព្រះអង្គម្ចាស់អង្គនេះ ដែលទំនងជាមិនចូលចិត្តក្លាយខ្លួនជាព្រះមហាក្សត្រ ។ នឹកស្រមៃតែនឹងការសិក្សារបាំ និងភ្លេង ព្រះអង្គបានទទួលព្រះរាជានុញ្ញាតឱ្យចុះឈ្មោះជាសិស្សសាលា Conservation de Prague ដ៏ល្បីជាងគេនៅអឺរ៉ុប នាពេលនោះ ។ ព្រះអង្គចេញពីកម្ពុជា កាលពីព្រះជន្មមិនដល់ដប់ឆ្នាំផង មិនបានប៉ុន្មានផង ស្រាប់តែព្រះអង្គចេញព្រះភក្រ្តជាដំបូងបង្អស់នៃប្រទេសឆេកូ ជាមួយក្រុម បាឡេ នៃភូស្តិ ក្នុងរបាំមួយឈ្មោះ Casse-Noisette ។ បន្ទាប់ពីទទួលបានរង្វាន់លេខ ១ ខាងរបាំក្លាសិក នាឆ្នាំ១៩៧១ ព្រះអង្គ ក៏បានចេញសម្តែងជាទៀងទាត់មកនៅ រោង អូប៉េរ៉ា នាទីក្រុង Prague ហើយផ្តើមបង្ហាញការចូលចិត្តតែងនាថកម្មរបាំ ហើយក៏ផ្តើមសរសេរ និត្ធេបទពីវប្បធម៌ និងរបាំរបស់ប្រទេសព្រះអង្គ ។

**នៅកម្លោះដូចតួឯកកុន ហង្សក្លូដ ប្រ៊ុយ៉ាលី**

ឡើងជាម្ចាស់នៃ "កម្ពុជាប្រជាធិបតេយ្យ" ភ្លាមក្រុមខ្មែរក្រហមផ្តើមបញ្ចប់វិជ្ជាជីវៈដ៏ជាទីសង្ឃឹមរបស់ព្រះអង្គភ្លាម ។ ទាក់ទាញដោយលិខិតតេឡេ-ក្រាមក្លែងក្លាយមួយ សីហមុនី ត្រូវបានបង្ខំចិត្តឱ្យយាងទៅចូលគាល់ព្រះបិតាព្រះមាតា នាឆ្នាំ១៩៧៥ ទៅជាប់ឯពន្ធនាគារជាព្រះបរមរាជវាំងនៅទីក្រុងភ្នំពេញ នាមាត់ទន្លេសាប ។ នៅទីនោះព្រះអង្គរក្សាព្រះជន្មជាមួយព្រះញាតិក្នុងការឃុំឃាំង និងក្នុងការភិតភ័យ មុននឹងបានភ្ជាប់ទំនាក់ទំនងទៅទីក្រុងប៉ារីស ជាមួយ





នឹងសិល្បៈរបស់ព្រះអង្គឡើងវិញ នៅឆ្នាំ១៩៨១ ។ ព្រះអង្គយាងទៅបង្ហាត់របាំនៅសាលា Coservations Marius-Petipa បង្កើតជាក្រុមរបាំផ្ទាល់របស់ព្រះអង្គមួយឈ្មោះ Ballet Petipa ព្រះអង្គនៅតែបង្ហាញការចូលចិត្តយ៉ាងជ្រាលជ្រៅចំពោះវប្បធម៌បុរាណខ្មែរ ដែលទទួលរងគ្រោះដោយសារអំពើផ្តាច់ការដ៏លីលាមួយ ។ ឆ្នាំ ១៩៩៣ ព្រះអង្គបានក្លាយជាឯកអគ្គរាជទូតខ្មែរ ប្រចាំអ៊ុយណេស្កូ តែព្រះអង្គនៅតែប្រើ "មេត្រូ" ជាព្រះទីនាំងសំរាប់ធ្វើដំណើរដដែល ។

គឺនៅខែតុលា ឆ្នាំ២004 ដែលខ្សែជីវិតត្រូវបានផ្លាស់ប្តូរ ដោយព្រះបិតា គឺព្រះមហាក្សត្រ នរោត្តម សីហនុ បានសម្រេចព្រះទ័យដាក់រាជ្យសម្បត្តិ ហើយព្រះអង្គម្ចាស់ក៏ត្រូវទទួលការតែងតែជាឯកច្ឆ័ន្ទ ដោយក្រុមប្រឹក្សារាជបល្ល័ង្គឱ្យឡើងរាជ្យបន្ត ។ ព្រះអង្គឧទ្ទានប្រាប់ទៅពេទ្យធ្មេញរបស់ព្រះអង្គមុននឹងវិចអឺរ៉ាន់ធ្វើដំណើរ ដោយប្រាប់ថា ខ្ញុំត្រូវចេញទៅ "មួយរយៈយ៉ាងវែង" ។

នៅពេលបោះបង់រាជ្យសម្បត្តិ មានព្រះរាជបំណងជាក់ច្បាស់មួយ គឺត្រូវរៀបចំអ្នកស្នងរាជ្យបន្តនៅពេលព្រះអង្គនៅមានព្រះជន្ម ។ មានបេក្ខជនដល់ទៅ៦0អង្គ ដែលរាយនៅក្នុងព្រះញាតិវង្សចំនួនបីដែលអាចមានសិទ្ធិជាព្រះមហាក្សត្រ តែអ្នកដែលឈ្នះ គឺត្រូវបំពេញលក្ខណៈសម្បត្តិ ថាជាអ្នកអាចចេះបន្ទាបខ្លួនគ្រប់គ្រាន់សំរាប់បំពេញចិត្ត ហ៊ុន សែន ដែលជាមនុស្សខ្លាំងក្នុងប្រទេស ដែលប្រឆាំងគ្រប់ការលូកដៃចូលធ្វើនយោបាយរាជវង្សផង ហើយមានបញ្ញា និងការប្រុងប្រយ័ត្នគ្រប់គ្រាន់សំរាប់ថែរក្សាស្ថាប័នរាជានិយម ដែលជាព្រះរាជបំណងដ៏ជ្រាលជ្រៅរបស់ សីហនុ ឱ្យបានផង ។ សីហមុនី បានបំពេញលក្ខណៈសម្បត្តិនោះ ។ នៅមានលក្ខខណ្ឌមួយទៀតដែលហាក់ដូចជាមានទម្ងន់ច្រើន គឺបំណងរបស់ សីហនុ ធ្លាប់មានមហេសីច្រើនផង មានព្រះរាជបុត្រាបុត្រីក៏ច្រើន តែព្រះអង្គចង់បង្ហាញការដឹងគុណដល់ព្រះអគ្គមហេសី មុនីនាថ ដែលបានឆ្លងកាត់វិញ្ញាសារដ៏លំបាកជាច្រើនជាមួយគ្នា ដោយការជ្រើសរើសព្រះរាជបុត្រមួយអង្គរបស់ព្រះអគ្គមហេសី ។

ឡើងជាព្រះមហាក្សត្រក្នុងព្រះជន្ម ៥១ព្រះវស្សា ដោយសារករណីកិច្ចជាព្រះរាជបុត្រអ្នកកម្លោះអង្គនេះនៅលីវដូច ហង្សក្លូដ ប្រ៊ុយ៉ាលី - រូបមន្តគឺមកពីព្រះបិតា - ព្រះរាជបុត្រ បានបំពេញតួនាទីចំនួន ៦ឆ្នាំ ប្រកបដោយវិចារណញ្ញាណ - ចែកកញ្ចប់អង្ករជូនប្រជារាស្ត្រក្រីក្រជាង គេនៅពេលយាងចេញតាមជនបទម្តងៗ - ការពារវប្បធម៌ខ្មែរ ឬក៏គង់ជាអ្នកការពារបរិដ្ឋាន... តែព្រះអង្គអផ្សុកណាស់ ! បំរើរាស្ត្រយ៉ាងភក្តី ខិតខំធ្វើអ្វីមួយឱ្យបានប្រសើរ... សីហមុនី មិនមែនជាមនុស្សម្នាក់ ដែលសប្បាយចិត្តនោះទេ ។ ព្រះអង្គមានបន្ទូលទៅបារាំងជាមិត្តរបស់ព្រះអង្គម្នាក់ថា "ការឃុំឃាំងនៅក្នុងពន្ធនាគារមាស ព្រះអង្គដឹងថា គ្មានមធ្យោបាយអ្វីដើម្បីនឹងបំបែកសំណល់នៃពិធីការដែលធ្វើឱ្យគាំងដំណើរនៃទំនាក់ទំនងព្រះញាតិវង្សព្រះអង្គ" ជាការពិតទៅព្រះអង្គមិនមានព្រះរាជបំណងឱ្យមានវិបត្តិអ្វីឡើយ ៕

NEW PHNOM PENH RESTAURANT
○មីបំពងគ្រឿងសមុទ្រ ○គុយទាវគោក -គុយទាវសាច់គោ
○ផាត់ថៃ ○ឡុកឡាក់ ○មាន់ឆាខ្ញី
○បាយសាច់ជ្រូកអាំង ○មីកន្តាំងសាច់គោ ○បាយឆាសាច់គ្រប់មុខ
TEL.(215) 389-2122
2301 South. 7th Street. Philadelphia, PA 19148
( 7th & Wolf)

NOEL TAX CONSUL TANTS
Financial Services
សេវាប្រកបដោយវិជ្ជាជីវៈ :
▸ ខ្ចីប្រាក់ទិញផ្ទះ MORTGAGE
▸ អន្តោប្រវេសន៍ IMMIGRATION
▸ បកប្រែភាសា TRANSLATION
▸ ធ្វើប្រថាប់ត្រាបញ្ជាក់លិខិតផ្លូវការ-NOTARY
▸ មានសេវាមើលកូន នឹងថែទាំផ្ទះសម្បែង
ណូអែល មជ្ឈមណ្ឌលសេវាធ្វើតាក់
សម្រាប់មុខរបរ ឬឯកជន-កត់ត្រាចំណូលចំណាយប្រចាំថ្ងៃនឹងប្រចាំត្រីមាស
អ្នកឯកទេសចំណាន នឹងធ្វើតាក់យ៉ាងប្រសើរជូនលោកអ្នក
អាសយដ្ឋាន : 6341RISING SUN AVE
Philadelphia . PA 1911
Phone : (215) 821-2443
Fax : (215) 821-2446
E-mail : noel.tax@gmail.com

ឱសថស្ថានខ្មែរ
Sav-Mor PHARMACY Tel: 215-467-1220
Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447
បំរើលោកអ្នកដោយមិត្តភាព និងតាន់ចិត្ត
▸▸Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
▸▸យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ
*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.

តមកទំព័រទី ០១

# ព្យុហយាត្រាដើម្បីផ្លាស់ប្តូរច្បាប់...

បានចូលរួមជាមួយអង្គការស្តែនិសមួយក្រុមឡើងឡានក្រុងពីគ្រឿង មានមនុស្សទាំងអស់ ១០០នាក់ ធ្វើដំណើរទៅ វ៉ាស៊ីនតោន ឌីស៊ី ដើម្បីចូលរួមធ្វើព្យុហយាត្រាយ៉ាងធំមួយពីរឿងធ្វើការផ្លាស់ប្តូរច្បាប់អន្តោប្រវេសន៍ កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១០ ។ មានប្រជាពលរដ្ឋគ្រប់សាសន៍ មកពីគ្រប់រដ្ឋក្នុងសហរដ្ឋអាមេរិក មានប្រមាណ ៧០ម៉ឺននាក់ ធ្វើព្យុហយាត្រានៅក្នុង Capital Hill ជាទីដែលព្រឹទ្ធសមាជិកអាមេរិកាំងអនុម័តច្បាប់សំរាប់សហរដ្ឋអាមេរិក ។

លោកប្រធានាធិបតី អូបាម៉ា បានសន្យាឱ្យមានការផ្លាស់ប្តូរនេះតាំងពីលោកបានធ្វើការឃោសនាធ្វើជាប្រធានធិបតី តាំងពីឆ្នាំ២០០៩ មកម្លេះ ។

ហេតុអ្វីក៏ត្រូវឱ្យមានការផ្លាស់ប្តូរច្បាប់នេះ ?

**ទី១ : គឺរឿងបែកបាក់គ្រួសារ :**

ឪពុកម្តាយដែលបានមកធ្វើការនៅទីនេះ ហើយថែមទាំងបានរៀបការជាមួយសញ្ជាតិអាមេរិកាំង ត្រូវបានរដ្ឋាភិបាលបណ្តេញឱ្យត្រឡប់ទៅមាតុភូមិគេវិញ ហើយបានបែកបាក់ប្រពន្ធកូន ធ្វើឱ្យសង្គមមានការអាប់អួ ។

**ទី២ : មានការមិនស្មើភាពគ្នារបស់កម្មករ :**

កម្មករអន្តោប្រវេសន៍ធ្វើការឥតមានភាពស្មើគ្នាត្រូវច្បាប់សហព័ន្ធ Minimum Wage ។ ក្រុមហ៊ុនបន្ទាបបន្ថោកតម្លៃការងារ ធ្វើឱ្យមានការពិបាកក្នុងការប្រកួតប្រជែងរវាងក្រុមហ៊ុន ។

**ទី៣ : បញ្ហាសេដ្ឋកិច្ច :**

ត្រូវការឱ្យសេដ្ឋកិច្ចក្នុងស្រុករីកចំរើន លូតលាស់ទៅមុខក្នុងផ្នែកកសិកម្ម ត្រូវតែមានកម្លាំងមនុស្សយ៉ាងច្រើន ដែលមានចិត្តធ្វើការច្រើនម៉ោង មានចិត្តធ្វើការតស៊ូ ហើយមានចិត្តចង់ធ្វើការ ។ តាំងតែពីសទវត្សរ៍ទី ៧០មក ឧស្សាហកម្ម ដូចជា មន្ទីរពេទ្យ ភោជនីយដ្ឋាន, ក្រុមហ៊ុនសេវាកម្ម និងផលិតកម្មនានា មានបញ្ហារកមនុស្សធ្វើការពិបាកខ្លាំងណាស់ ដោយសារក្នុងពេលថ្មីៗនេះ ជនជាតិអាមេរិកាំង ចូលនិវត្តន៍ច្រើនណាស់ ដូចជា ក្រុមចាស់ដែលកើតក្នុងអំឡុងឆ្នាំ១៩៤៦ ដល់ឆ្នាំ១៩៨៦ (Baby Boomer) ។

**ទី៤ : សន្តិសុខជាតិ :**

មានអ្នកជំនួញខុសច្បាប់ចូលមកធ្វើឱ្យនៅតាមព្រំដែន មានការពិបាកធ្វើការដល់ក្រសួងសន្តិសុខជាតិ ។ មានការពិបាកបែងចែកឱ្យច្បាស់លាស់រវាងអ្នកមករស់នៅ ក្នុងន័យរកស៊ីចិញ្ចឹមគ្រួសារ និងអ្នកមកចង់បង្កើតអសន្តិសុខ ។

យើងបានធ្វើការសង្កេតមួយដែលគួរកោតសរសើរ ម្យ៉ាងទៀតដែរ របៀបធ្វើការរបស់ពួកគេក្នុងការស្វែងរកមធ្យោបាយដោះស្រាយបញ្ហាសង្គមរបស់គេដោយសន្តិវិធី ដោយគ្មានការធ្វើបាបដល់ក្រុមបាតុករទាំងនោះឡើយ ហើយថែមទាំងមានអាជ្ញាធរក្រុងតាមជួយការពារសន្តិសុខផង ។ នេះហើយដែលយើងទាំងអស់គ្នាគួររៀនសូត្រ ហើយយកមកអនុវត្តន៍ក្នុងសង្គមប្រទេសជាតិយើង ៕













ឌឹ ខេមបូឌា ដេលី The Cambodia Daily

## Defense Seeks Sanction of Tribunal Prosecutors

By Douglas Gillison
The Cambodia Daily

Lawyers for former Khmer Rouge Foreign Minister Ieng Sary announced Wednesday they were asking the Khmer Rouge tribunal to sanction prosecutors for allegedly undertaking "impermissible investigations."

While prosecutors perform preliminary inquiries in order to open judicial investigations, prosecutors and all parties to the trials are prohibited from independently investigating the allegations that are the subject of inquiries by the court's co-investigating judges.

The Ieng Sary defense, lawyers Michael Karnavas and Ang Udom, were themselves threatened with sanction in February, partly in response to their proposal that they be allowed to collect evidence independently. They have repeatedly charged that the investigation is biased in favor of the prosecution and sought to introduce their own evidence.

In a statement posted to their independent website, which was created last year in an effort to circumvent the court's restrictions on public information, the defense announced they had asked that prosecutors be sanctioned for allegedly investigating evidence independently of Co-Investigating Judges You Bunleng and Marcel Lemonde, who concluded their investigation of Ieng Sary and four other detainees in January.

According to the defense, prosecutors recently sought to admit into evidence 849 documents and a database containing 3,983 records of forced confessions from S-21 prepared by historian David Chandler, the defense said in a statement.

Prosecutors' "possession of some of this material appears to demonstrate that the [prosecution] has continued to investigate into Case 002 despite the [investigating judges'] prohibition on party-conducted investigations," the defense wrote in a summary of their pleadings, which alleged prosecutors' actions gave them an unfair advantage over the defense.

The lawyers noted they had received harsh warnings in February for similar reasons and asked the prosecution be treated the same way.

"The defense has no other means to ensure that its rights are protected," they wrote.

Prosecutors have yet to respond to Wednesday's motion.

However, the Ieng Sary defense in June were unsuccessful in seeking sanctions against the prosecution, whom they accused of deliberately suppressing information they supposedly knew would disfavor their arguments on a contested form of criminal liability.

That motion was ultimately denied after a lawyer involved denied the allegations.

## ក្រុមស្វែងរកការដាក់ទណ្ឌកម្មព្រះរាជអាជ្ញាសាលាក្តីបន្ថែមទៀត

ដោយ : Douglas Gillisom
The Cambodia Daily

ក្រុមមេធាវីរបស់លោក អៀង សារី អតីតរដ្ឋមន្ត្រីការបរទេសខ្មែរក្រហម បានប្រកាសកាលពីថ្ងៃពុធ ថាពួកគាត់កំពុងស្នើឱ្យសាលាក្តីខ្មែរក្រហមដាក់ទណ្ឌកម្មព្រះរាជអាជ្ញាមួយចំនួនចំពោះ ការដែលគេចោទថា ធ្វើការ "ស៊ើបអង្កេតដោយគ្មានការអនុញ្ញាត" ។

ខណៈដែលព្រះរាជអាជ្ញាធ្វើការសាកសួរដំបូងដើម្បីបើកការស៊ើបអង្កេតរបស់តុលាការនោះ ក្រុមព្រះរាជអាជ្ញារបស់តុលាការ និងភាគីទាំងអស់ដែលចូលរួមសវនាការត្រូវហាមឃាត់មិនឱ្យធ្វើការស៊ើបអង្កេតដោយឯករាជ្យចំពោះការចោទប្រកាន់ដែលជាប្រធានបទនៃការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតរបស់តុលាការនោះទេ ។

មេធាវីការពារលោក អៀង សារី គឺលោក ម៉ៃឃើល កាណាវ៉ាស និងលោក អង្គ ឧត្តម ត្រូវបានគំរាមកំហែងដាក់ទណ្ឌកម្មកាលពីខែកុម្ភៈ មួយផ្នែកជាការឆ្លើយតបនឹងសំណើរពួកគាត់សុំអនុញ្ញាតឱ្យពួកគាត់ប្រមូលភស្តុតាងដោយឯករាជ្យ ។ តាមព័ត៌មានថា ពួកគាត់បានចោទម្តងហើយម្តងទៀតថា ការស៊ើបអង្កេត គឺលំអៀងដោយគាំទ្រអយ្យការ ហើយស្វះស្វែងរកភស្តុតាងដោយខ្លួនឯង ។

នៅក្នុងសេចក្តីថ្លែងការណ៍មួយដាក់តាមវិបសាយឯករាជ្យរបស់ពួកគាត់ ដែលត្រូវបានបង្កើតឡើងកាលពីឆ្នាំមុន ជាការខំប្រឹងដើម្បីជៀសវាងពីការដាក់កម្រិតរបស់តុលាការលើព័ត៌មានសាធារណៈនោះ ក្រុមមេធាវីនេះបានប្រកាសថា ពួកគាត់ស្នើឱ្យមានការដាក់ទណ្ឌកម្មព្រះរាជអាជ្ញាមួយចំនួនចំពោះការដែលគេចោទថា បានស៊ើបអង្កេតរកភស្តុតាងដោយឯករាជ្យពីសហចៅក្រមស៊ើបអង្កេតលោក យូ ប៊ុនឡេង និងលោក ម៉ាសែល ឡឺម៉ុង ដោយបានបញ្ចប់ការស៊ើបអង្កេតរបស់ពួកគាត់លើលោក អៀង សារី និងអ្នកជាប់ឃុំ៤នាក់ទៀតកាលពីខែមករា ។

ក្រុមនេះបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍មួយថា នៅពេលថ្មីៗនេះ ព្រះរាជអាជ្ញាមួយចំនួន បានស្វះស្វែងឱ្យមានការទទួលយកឯកសារភស្តុតាងចំនួន៨៤៩ និងទិន្នន័យមួយដែលមានកំណត់ត្រាសារភាពដោយបង្ខំចំនួន៣.៩៨៣ ពីស.២១ ដែលត្រូវបានរៀបរៀងដោយអ្នកប្រវត្តិសាស្ត្រ ដេវិត ឆានល័រ ។

ក្រុមនេះបានសរសេរនៅក្នុងសេចក្តីថ្លែងការណ៍សង្ខេបរបស់ពួកគេ ដែលអះអាងថា សកម្មភាពរបស់ព្រះរាជអាជ្ញាមួយចំនួនបានផ្តល់ឱ្យពួកគាត់នូវគុណសម្បត្តិមិនត្រឹមត្រូវលើការការពារក្តីនេះថា ការទទួលបានគុណសម្បត្តិមួយចំនួនក្នុងចំណោមគុណសម្បត្តិនេះរបស់ព្រះរាជអាជ្ញា ហាក់បីដូចជាបង្ហាញថា (អយ្យការ) បានបន្តស៊ើបអង្កេតនៅក្នុងរឿងក្តី០០២ ថ្វីបើមានការហាមឃាត់របស់ (ចៅក្រមស៊ើប-អង្កេតលើការស៊ើបអង្កេតដែលធ្វើឡើងដោយភាគីម្ខាង) ក៏ដោយ ។ ក្រុមមេធាវីបានបញ្ជាក់ថា ពួកគាត់ត្រូវបានផ្តល់ការព្រមានខ្លាំងៗកាលពីខែកុម្ភៈ ចំពោះហេតុផលស្រដៀងគ្នានេះ ហើយបានស្នើឱ្យមានការដាក់ទោសព្រះរាជអាជ្ញាតាមវិធីដូចគ្នា ។ ពួគគាត់បានសរសេរថា "ក្រុមមេធាវីគ្មានមធ្យោបាយផ្សេង ដើម្បីធានាថា សិទ្ធិរបស់ត្រូវបានការពារទេ" ។ ក្រុមព្រះរាជអាជ្ញាមិនទាន់បានឆ្លើយតបទៅនឹងសំណើរកាលពីថ្ងៃពុធនោះទេ ។

ទោះជាយ៉ាងណា នៅក្នុងខែមិថុនា ក្រុមមេធាវីលោក អៀង សារី បានបរាជ័យក្នុងការស្វែងរកការដាក់ទណ្ឌកម្មប្រឆាំងព្រះរាជអាជ្ញាដែលពួកគាត់បានចោទថា បានរារាំងដោយចេតនានូវព័ត៌មានដែលពួកគាត់ដឹងថា នឹងធ្វើឱ្យខូចដល់ទឡ្ហីករណ៍របស់ពួកគាត់លើប្រភេទដែលតវ៉ានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ។ សំណើនេះត្រូវបានបដិសេធក្រោយពីមេធាវី ដែលបានចូលរួមបានបដិសេធការចោទប្រកាន់នោះ ៕

## នៅពេលដែល ជីដូន ចូលមរណភាព

•••នៅពេលជីដូនស្លាប់ទៅ រ៉ូណល ជិន អាយុ ១៤ ឆ្នាំ ជាចៅប្រុស និងជាកូនច្បងរបស់ វុត្ថា និង រ៉ន បានធ្វើការសង្កេត ពិចារណា ហើយរៀបរាប់ពីព្រឹត្តិ-ការណ៍ "ជីដូន" ដែលបានធ្វើមរណកាលទៅនោះ ។ តាមរយៈអត្ថបទតែងឡើងដោយ រ៉ូណល ជាភាសាអង់គ្លេស ចាស់ទុំអាចមើលឃើញថា អ្វីដែលសំខាន់ អ្វីដែលជាការចូលចិត្ត ហើយអ្វីជាការចម្លែករបស់យុវជន រស់ធំធាត់នៅសហរដ្ឋអាមេរិក ដើម្បីចូលរួមចំណែកក្នុងវប្បធម៌ថ្មីមួយ ដែលក្រុមគ្រួសារអាចយល់គ្នាទៅវិញទៅមកបាន ។

When She Die

By Ronald Chin, 14, Wutha and Rorng's older son

It didn't really hit me that hard. Finding out she died was like finding out any everyday information. The start of summer vacation or going to Florida would probably have exited me more. I don't know why. Information like that isn't just something you take and then just go about your day like nothing happened. I was on my Xbox racking up points in a multiplayer match. There was some excitement in that. I almost won the match too when my dad came home. He called us down and I turned it off. I didn't accumulate any of the points from the game into the career stats. Funny thing about this though, it's kind of a stupid thing to worry about when you've found out your Great-grandmother had died. I remember my dad calling us to him. He took my brother in his arms and they cried. That was very different. And I knew something was wrong. My dad never cried. I knew exactly what had happened at that point. Nothing was special really. Only my dad just lost the person who took care of him and his brother when his parents were taken by the Khmer Rouge in Cambodia. The person who made sure they ate and survived as they ran and lived in refugee camps. Only the person who made sure they went to school, got jobs and didn't get into the fights or get killed, despite the racists that didn't want my dad and his brother to succeed. Yeah, she just the person who's the reason why my dad and uncle are alive; and the reason of why I'm here.



At the viewing, my dad wanted everyone to wear black. Half of the kids wore dresses with flowers and colorful sweaters as if they were going to school for the first time. It's kind of harsh to say, but only her immediate family, friends, and several people from the temple really gave a shit. Others just came out of respect, or they were told to. I wish more people cared. But you can't have everything right? I remember seeing her for the first time out of her hospital bed (which was only a day before she died). She looked…normal. Like as if she was sleeping. The lady who prepared everything did a good job, except that my great-grandmother was wearing makeup (a mistake by the lady; she never wore makeup), and her skin was hardened by the embalming. When I last saw her, she was stricken by a stroke that left her in an awkward disposition and posture. She couldn't move the whole half of her body or talk. My mom had to help her hold my hand. I wanted to cry when I saw that. And I won't forget it.



When the day of cremation came, I helped carry her casket to the limousine. We drove like a convoy, over 20 cars, with my dad leading the way. The guys at the cemetery probably did cremations pretty often. They had a building with a reception room painted and furnished like a home. Complete with restrooms and chandeliers. The technicians, workers, what ever you want to call them, wore faces as if they mourned her loss with us. Couldn't blame them for trying, they were simply doing their job.

With her casket centered in the front of the room, several monks sang prayers and chants while we watched. The man who ran the funeral home became impatient and left. At least his employees did a better job than he did.

The hum of the burners sang in the background. It was unsettling. The two workers lined up her casket to the shutter door. A few words said, the boss of the funeral home rammed her in with unnecessary harshness, and threw in some flowers for good measure. And as a symbolic gesture, my father pressed the button as we all watched. Behind that door, one of the most important people in my life lit up in flames. When we walked out, snacks and drinks were waiting for us. My cousin was getting ready to go to a block party at her street. The adults stood in circles and talked, even gossiped. And I just stood there among these people in my black shirt, shoes, and jacket. I've never felt more lost about what the hell was going on in my entire life.

But that is behind me now. I've thought about many things. More people I know will die, I'm sure. Friends, family, and other people I'm going to meet down the road. But dealing on these things impairs the true meaning of moving forward. And I want to move forward. My future is not guaranteed and it's hard to envision myself older. But in all the blindness of things I know one thing for sure. I'm going to live to as old as she did. I want to affect people the way she affected me. And in the time between that day, and the day I die, I want to do as many amazing things or affect as many people as humanly possible. To live her unspoken legacy is my main goal now. I've never felt so sure about something in my entire life.

# អាថ៌កំបាំង និងសិល្បៈនៃជីវិត
# SECRET AND ART OF LIVING



(តមកពីលេខមុន)

រៀបរៀងដោយ
លោក ម៉ៅ ច័ន្ទសំណុំ

•••ភាពមុឺងម៉ាត់ទេនោះ ចិត្តពីខាងក្នុង នឹងបង្គាប់លោកអ្នកឱ្យបោះបង់ការអានជាពុំខាន ឡើយ ដូចជាបន្លឺសំឡេងប្រាប់ថា "អានបានការអ្វីវា សុទ្ធតែជាគំនិតរវើរវាយផ្តេសផ្តាសតែប៉ុណ្ណោះ យក ពេលវេលាគិតគូររឿងផ្សេងវិញប្រសើរជាង" ។ ម្យ៉ាងទៀត សូមអានតាមលំដាប់លំដោយកុំរំលង ព្រោះមានពាក្យខ្លះទាមទារការពន្យល់បន្តបន្ទាប់ ។ ដោយការស្រាវជ្រាវនេះផ្តើមចេញពីឯកសារនានា ជាភាសាអង់គ្លេស ខ្ញុំសូមបញ្ចូលពាក្យអង់គ្លេសគន្លឹះ ខ្លះសំរាប់ជាជំនួយដល់ការស្រាវជ្រាវនានាបន្ត និង ងាយយល់ស៊ីជំរៅនូវបាតុភូត និងពិភពផ្លូវចិត្តនេះ ។ មានចំណុចខ្លះ ខ្ញុំបានរៀតបរាប់ជ្រាំដែលច្រើនសារ ក្នុងបំណងប្រាប់អ្នកថា នោះជាចំណុចសំខាន់បំផុត ហើយចង់ឱ្យគំនិត និងទស្សនៈទាំងឡាយនោះ ចូល ជ្រៅក្នុងអារម្មណ៍អ្នកផង ។

I. **អាថ៌កំបាំងនៃជីវិត**

ខ្ញុំដកស្រង់ទស្សនៈ និងគំនិតមូលដ្ឋានទាំងនេះ ចេញពីព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា និងចិត្តសាស្ត្រសម័យទំនើប ។ មុននឹងចូលលំអិតសាច់រឿង គួរលោកអ្នកជ្រាបថា អំពីពាក្យមួយម៉ាត់ ដែលភាសា អង់គ្លេសហៅថា Consciousness ភាសាខ្មែរយើង ពុំមាននិយមន័យច្បាស់លាស់ទេ ។ តាមវចនានុក្រម អង់គ្លេស-ខ្មែររបស់លោក ជីវ សៀន ឆ្នាំ២000 បាន បញ្ជាក់ថា Consciousness មានន័យថា សតិស្មារតី ។ ក្នុងភាសាអង់គ្លេស បើខ្ញុំនិយាយថា I am Conscious ស្មារតី ខ្ញុំដឹងខ្លួន ។ I am unconscious ខ្ញុំពុំដឹងខ្លួន គ្មានស្មារតី ។ I am Conscious of the situation ខ្ញុំដឹង ឬជ្រាបពីស្ថានការណ៍ ។

អ្នកប្រាជ្ញវិទ្យាសាស្ត្រ និងសាសនានានា បាន ណែនាំឱ្យយើងសង្កេតបាតុភូតធម្មជាតិ មានដូចជា មនុស្ស សត្វ រុក្ខជាតិ ភ្នំ ផ្កាយ ព្រះអាទិត្យ ព្រះច័ន្ទ មានដំណើរ ចលនា កើត រីកលូតលាស់ ស្លាប់ វិនាស តាមក្រិតមួយជាកំណត់ ។ ហេតុអ្វីព្រះច័ន្ទវិលជុំវិញ ព្រះអាទិត្យ ហើយមានដំណើរយ៉ាងទៀងទាត់ (៣៦៥ថ្ងៃ ក្នុងមួយជុំព្រះអាទិត្យ) ។ ផ្កាធម្មជាតិខ្លះ មានពណ៌លំអរគួរឱ្យស្ញើចសរសើរហួសអំពីការស្មាន ។ តើដែលឆ្ងល់ថា ហេតុអ្វីក៏ច្រមុះមនុស្សគ្រប់រូប ឋិត នៅតែលើមុខមន្សា ហើយពុំឋិតនៅជើង ឬពោះ? តើនរណាចាត់ចែងដំណើរឈាមរត់ ដំណើរ បេះដូង ដំណើររំលាយអាហារ ដំណើរដកដង្ហើមក្នុងខ្លួនមនុស្ស យើងម្នាក់ៗ? បាតុភូតធម្មជាតិទាំងអស់នេះ ចលនា តាមក្រឹតក្រមកំណត់មានដំណើរល្អឥតខ្ចោះ ទៀងទាត់ ហាក់ដូចជាមាន **កម្លាំងអ្វីមួយ** ចាត់ចែង រៀបសំរួលពី ខាងក្រៅ ប្រៀបដូចជាវង់ភ្លេង ដែលប្រគុំតន្ត្រីដ៏ពីរោះ ក្រោមការដឹកនាំដោយមនុស្សម្នាក់ដ៏ប៉ិនប្រសប់ ឈរ បញ្ជាពីមុខក្រុមភ្លេង (Orchestrator) ។ បើយើង ពិនិត្យទៅឃើញថា នៅពីក្រោយបាតុភូតទាំងអស់ នោះៗ មានវត្ថុមួយរួមបំផុត គឺកម្លាំង និងថាមពល Force and Energy (or Prana= Vita force) ដែលមានដំណើរប្រែប្រួលពីបាតុភូតមួយទៅបាតុភូត មួយទៀត បន្តបន្ទាប់ រាប់មុឺន សែន លានបែបរាប់មិន អស់ ។ ឧទាហរណ៍ ព្រះអាទិត្យបញ្ចេញថាមពលមក លើចក្រវាឡ គឺវានេះហើយដែលជាកម្លាំងចលករ បង្កប់ក្នុងសត្វ រុក្ខជាតិ និងធម្មជាតិនានា ។ ហើយ មនុស្សយើងដើម្បីចលនាទៅបានត្រូវឱ្យហូបអាហារ ដែលជារូបភាពថាមពលពីធម្មជាតិ (ប្រៀបដូចរថយន្ត ត្រូវការប្រេងឥន្ធនៈ) ។ អ្នកប្រាជ្ញផ្លូវលោក និង សាសនាបានសន្និដ្ឋានថា មានកម្លាំងមួយទៀត រួម បំផុត (តែមួយគត់) ធ្វើសកម្មភាព ចាត់ចែង បញ្ជានៅ ពីខាងក្រោយចលនាថាមពលនោះ នោះគឺបាតុភូត **កុងស្យនិស** Consciousness **ឬជាជីវិត** ។ មើលចុះ ជីវិតមានគ្រប់ទិសទី មានរូប ឥតរូប ក្នុងថ្ម លើដី ក្នុង អាកាស សត្វ រុក្ខជាតិ មនុស្ស ថ្មភ្នំ ត្បូង ។ល។

ដូច្នេះពាក្យ **Consciousness** មានន័យទូលំទូលាយក្តោបរហូតដល់ជីវិតទៀតផង ។ ពួកព្រាហ្ម តែឱ្យដឹងថា **Consciousness** (កុងស្យនិស) ជា បណ្តូលនៃជីវិតអ្វីៗទាំងអស់ មានមនុស្ស សត្វ រុក្ខជាតិ ក្នុងពិភពធម្មជាតិចក្រវាឡយើងនេះ ។ ដោយឡែក មនុស្សយើងម្នាក់ៗមាន **Consciousness** (កុងស្យនិស) ឬជីវិតជាប់នឹងខ្លួន តាំងពីកើតរហូតដល់ ស្លាប់ទៅវិញ ។ ដោយសារកុងស្យនិស ឬជីវិតនេះ ហើយ ទើបមានចលនាកើតរីកលូតលាស់នៃ រូបកាយ មានដំណើរវិញ្ញាណទាំង៥ ម៉េម៉ូរី (ការចងចាំ) ការដឹង លំហូរគំនិត ប្រតិកម្ម ការរំជួលចិត្ត វេទនា ទស្សនៈ ទាន ។ល។ The ultimate source of all time ។

សូមចូលរួមពិសោធន៍ជាមួយខ្ញុំអំពីការមើលទៅ ក្រៅ ។ យើងសួរថា នរណាមើល? ចម្លើយគឺភ្នែក មើល ប៉ុន្តែបើមុចចូលទៅក្នុងខ្លួនបន្តិចទៀត យើង មានមានសមត្ថភាពអាចមើលផ្ទៃកពីខាងក្នុងមកបាន អាចដឹងថា ភ្នែកបើក ឬព្រិច ឬបិទ ចុះនរណាមើល ពីក្នុងមក? (យើងដេញតាមសួរ) មានអ្នកមើលពី ក្នុងមក ពិតណាស់ ព្រោះឃើញពិសោធន៍ឃើញជាក់ ស្តែង ។ ក្នុងទីនោះយើងពិសោធន៍ដឹងថា កំហឹង ភ័យ បារម្ភ សប្បាយលេចឡើង ហើយរលាយបាត់ទៅ ។ល ។និង ។ល ។ ដូច្នេះមានវត្ថុមាននរណាម្នាក់មើល ពីក្នុងមក វាជាប្រភពនៃការពិសោធន៍ការមើលការ ទទួលដឹងថា មានអ្វីកំពុងកើតមាននៅខាងក្រៅខ្លួន នៅលើខ្លួន និងនៅខាងក្នុងខ្លួន ។ នោះ គឺបាតុភូតកុងស្យនិស Consciosness ក្នុងរូបមនុស្សយើងម្នាក់ៗ ។ បើយើងអស់ជីវិតភ្លាម គ្មានកុងស្យនិសទៀតឡើយ គ្មានចិត្ត គ្មានអារម្មណ៍ គ្មានគំនិត គ្មានវេទនា ហើយ រូបកាយនឹងរលាយចូលទៅក្នុងធម្មជាតិវិញ (ជីវិតបន្ត ទៅទៀត គ្រាន់តែប្រែរូបភាពនៃថាមពលប៉ុណ្ណោះ) ។

(តទៅលេខក្រោយ)

# Gary Ung ឬ Anthony Kim ជាកុងស៊ុលនៅ Long Beach?

ក្រុងខ្មែរ, ខ្មែរប៉ុស្តិ៍ : មាជ សុវណ្ណារ៉ា

•••ប្រភពដែលខ្មែរប៉ុស្តិ៍ទទួលបានពីក្រសួងការ បរទេសកម្ពុជា ក៏ដូចពីខុទ្ទកាល័យរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន គ្រោងនឹងរៀបចំឱ្យមានទីស្នាក់ការកុងស៊ុល មួយនៅទីក្រុង Long Beach ក្នុងពេលឆាប់ៗ ប៉ុន្តែ ប្រភពមិនទាន់បង្ហើបឱ្យដឹងប្រាកដថា ថ្ងៃណា ខែណា ទេក្នុងឆ្នាំនេះ ។ ក្នុងខណៈដែលអតីតកាលកុងស៊ុល ខ្មែរដែលបានបើកម្តងទៅហើយ កាលពីដើមទសវត្ស ឆ្នាំ2000 ហើយក៏ត្រូវបានបិទទៅវិញ មិនបានប៉ុន្មាន ឆ្នាំផងនៅទីក្រុង Los Angeless ព្រោះតែកង្វះខាត ថវិកាគាំទ្រ រួមទាំងការចោទប្រកាន់ថា បើកកុងស៊ុល ដើម្បីបម្រើគណបក្សប្រជាជនកម្ពុជា ជាមួយការខ្វះ ខាតការគាំទ្រ និងសហការពីសហគមន៍ខ្មែរទៀតនោះ ។

ប្រភពបង្ហើបឱ្យដឹងទៀតថា មនុស្ស2រូប ជាអ្នក រស់នៅទីក្រុង Long Beach ដែលម្នាក់ជាអ្នកជំនួញ គឺ Gary Ung និងម្នាក់ទៀតជាអ្នករដ្ឋការរបស់រដ្ឋ California គឺ Anthony Kim កំពុងប្រកួតប្រជែង គ្នាតាមរយៈខ្សែបណ្តាយរបស់ខ្លួននៅឯប្រទេសកម្ពុជា ដើម្បីទាក់ទាញយកតំណែងជាកុងស៊ុលប្រចាំនៅក្រុង Long Beach សម្រាប់តំណាងឱ្យរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើកិច្ចការការទូតក្នុងការសម្រួលដល់ផ្នែក ទំនាក់ទំនងដល់សហគមន៍ខ្មែរក្នុងសហរដ្ឋអាមេរិក និងជាតិសាសន៍ដទៃមិនថា ការចង់ដឹងពីស្ថានការ នយោបាយនៅកម្ពុជា ឬក៏សម្រួលដល់កិច្ចការអន្តោប្រវេសន៍ លិខិតឆ្លងដែន និងការទំនាក់ទំនងធ្វើជំនួញ ជួញដូរនៅកម្ពុជាជាដើម ។

បេក្ខជនកុងស៊ុលលោក Gary Ung បានថ្លែងប្រាប់ ខ្មែរប៉ុស្តិ៍ឱ្យដឹងថា ក្នុងសង្គមប្រជាធិបតេយ្យ ដើម្បី ជ្រើសរើសជាមេដឹកនាំ ឬជាអ្នកតំណាងដើម្បីបម្រើ ផលប្រយោជន៍សង្គមខ្មែរ វាត្រូវតែមានការជ្រើស រើសប្រកួតប្រជែងទៅតាមសមត្ថភាព បទពិសោធន៍ ការងារ និងលក្ខណៈសម្បត្តិរបស់មនុស្ស ។



លោក Gary Ung



លោក Anthony Kim

លោក Gary Ung បានបញ្ជាក់ថា "ចំពោះខ្ញុំវាជា រឿងធម្មតានៃការប្រកួតប្រជែងដោយមិនចង់ឈ្នះ-ចាញ់អ្វីទេ ដោយស្រេចលើរាជរដ្ឋាភិបាលកម្ពុជាជា អ្នកវិនិច្ឆ័យក្នុងការសម្រេច ថាតើបេក្ខជនមួយណា ដែលរាជរដ្ឋាភិបាលកម្ពុជា មើលឃើញថាល្អប្រសើរ ។ ដោយខ្ញុំសូមបញ្ជាក់ថា បេក្ខជនខ្ញុំនេះមានការគាំទ្រ ពីសមាគមនានានៅទីក្រុង Long Beach និងពួកអ្នក នយោបាយគណបក្សនានាដែលចង់ឃើញឱ្យខ្ញុំចូល ប្រឡូកឱ្យជ្រៅជួយដល់សហគមន៍ខ្មែរដើម្បីរួបរួមគ្នា ធ្វើកិច្ចសហការខ្មែរក្នុង ឬខ្មែរក្រៅប្រទេស គឺខ្មែរ តែមួយដែលខ្ញុំចង់ឃើញខ្មែរឈ្នះក្នុងការអភិវឌ្ឍន៍ ការសាមគ្គីភាពគ្នា" ។

ក្នុងសំណួរចោទសួរថា តើលោកមានការបារម្ភពី គូប្រជែងម្ខាង ដែលជាសែស្រឡាយសាច់ញាតិរបស់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ផងនោះ តើមានក្តី សង្ឃឹមទេ ? លោក Gary Ung បានបញ្ជាក់ថា វាជា ក្តីសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំមិន បញ្ចេញមតិយោបល់ទេ ! ហើយមិនចង់ឈ្នះ ចាញ់ទេ អ្នកណាមួយកាន់តំណែងឯកអគ្គកុងស៊ុលក៏បាន ពោល គឺខ្ញុំចង់ឃើញប្រជាពលរដ្ឋជាអ្នកឈ្នះក្នុងការកសាង សហគមន៍ខ្មែរដែលកុងស៊ុលជាអ្នកបម្រើពលរដ្ឋតាម បែបលទ្ធិប្រជាធិបតេយ្យ ។

កាសែតខ្មែរប៉ុស្តិ៍បានព្យាយាមទូរស័ព្ទជាច្រើន ដងទៅលោក Anthony Kim ដែលជាបេក្ខជនម្នាក់ ទៀតសម្រាប់តំណែងជាកុងស៊ុលដែរនោះ ដើម្បីសុំ ការអត្ថាធិប្បាយ ប៉ុន្តែរូបលោកពុំបើកទូរស័ព្ទឆ្លើយ តបតមកវិញទេ ក្រៅពីដាក់សំឡេងសារនោះ ។

Anthony Kim បច្ចុប្បន្នធ្វើការនៅក្រសួង Child Support របស់រដ្ឋ California រូបលោក ធ្លាប់បរាជ័យក្នុងតំណែងឈរឈ្មោះជាបេក្ខជនចៅ សង្កាត់ទី2នៃក្រុង Long Beach កាលពី 4-5ឆ្នាំ មុននោះ ដែលប្រភពបង្ហើបថា បុរសរូបនេះអាច សង្ឃឹមថានឹងក្លាយជាកុងស៊ុល ព្រោះភរិយារបស់គាត់ ជាសាច់ញាតិជាមួយឪពុករបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺព្រឹទ្ធាចារ្យ ហ៊ុន នាង ។ ព្រោះការចោទ ប្រកាន់ថា ប្រទេសកម្ពុជាចាំបាច់ណាស់ពីការពឹងពាក់ តាមរយៈខ្សែបណ្តាយបក្សពួកនិយម បើយើងចង់ ធ្វើការងារ ឬសម្រេចអ្វីមួយនោះ ។

ចំណែកឯ Gary Ung វិញប្រភពបាននិយាយថា រូបលោកក៏មានបក្សពួក និងអ្នកគាំទ្រមិនតិចដែរនៃ ខ្សែបណ្តាយដែលមានលោករដ្ឋលេខាធិការនៃទីស្តី ការគណៈរដ្ឋមន្ត្រី ដែលជាមនុស្សស្និទ្ធនិងលោក សុខ អាន នៅពីក្រោយការជួយជំរុញឱ្យ Gary ក្លាយទៅ ជាកុងស៊ុលនោះ ។

អ្នកច្បាប់ម្នាក់សុំមិនបញ្ចេញឈ្មោះប្រាប់ខ្មែរប៉ុស្តិ៍ ឱ្យដឹងថា ការដាក់បេក្ខជនបង្ហាញទៅរដ្ឋាភិបាល កម្ពុជាវាអាស្រ័យតាមរយៈលោកឯកអគ្គរាជទូតខ្មែរ ប្រចាំសហរដ្ឋអាមេរិកក្នុងការស្នើសុំទៅប្រមុខរាជរដ្ឋាភិបាលតាមរយៈក្រសួងការបរទេសខ្មែរក្នុងការ ជ្រើសរើសកុងស៊ុលនេះ ។ ដូច្នេះឯកអគ្គរាជទូត

(តទៅទំព័រទី ១៧)

នាទី ប្រវត្តិសាស្ត្រ

# ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

**ប្រែសម្រួលដោយ : ពិន សំខុន (តពីលេខមុន)**

. រដ្ឋមន្ត្រីសង្គមកិច្ច : ខៀវ ធីរិទ្ធ

. រដ្ឋមន្ត្រីវប្បធម៌-អប់រំ និងសិក្សាធិការ : យុន យ៉ាត

. រដ្ឋមន្ត្រីសុខាភិបាល : ជួន ជឿន

. រដ្ឋមន្ត្រីយុត្តិធម៌ : កង ចាប

. បណ្តាប្រធានគណៈកម្មាធិការមានឋានៈស្មើរដ្ឋមន្ត្រីគឺ :

. សាធារណការ : តូច ភឿន

. កសិកម្ម : នង សួន

. ឧស្សាហកម្ម : ចេង អាន

. ពាណិជ្ជកម្ម : កុយ ធួន

. គមនាគមន៍ : ម៉ី ព្រេង

. ចំការដំណាំ : ភួង

- ២៤ មេសា : ដាក់ចំណងស្ថានទូតជាមួយប្រទេសភូមា ។

- មេសា - ឧសភា : សកម្មភាពឃុបឃិត ទម្លាក់ ប៉ុល ពត តែត្រូវគេរកឃើញ ។

- ១ ឧសភា : ដាក់ស្ថានទូតជាមួយ ម៉ាឡាយូ ។

- ៤ ដល់ ១៨ ឧសភា : ពិភាក្សាទ្វេភាគី នៅភ្នំពេញ រវាងខ្មែរ និងវៀតណាម ស្តីពីរឿងព្រះប្រទល់ដែន ក្នុងគម្រោងជំនួបកំពូលនៅខែមិថុនា ។ កិច្ចព្រមព្រៀងនៅលើដំណើរការណ៍របស់គណកម្មាធិការព្រំដែនរួមគ្នា ក៏ប៉ុន្តែភាគីវៀតណាម មិនទទួលស្គាល់គំនូសរដ្ឋបាលបារាំង ស្តីអំពីបន្ទាត់ ប្រេវិយេ - ភាគីខ្មែរ បានបញ្ចប់កិច្ចចរចាគ្នា ។

- ៥ ឧសភា - ២៦ មិថុនា : ដាក់ទូតជាមួយ ហ្វីលីពីន - សិង្ហបុរី - ប៉េរ៉ូ និង ឈីលី - អ៊ីតាលី ។

- ២០ ឧសភា : ចាប់ខ្លួនចក្រីនាយសេនាធិការកងទ័ពរង ។

- ២០ កក្កដា : ប៉ុល ពត ទទួលក្រុមអ្នកកាសែតវៀតណាម ។

- ២០ សីហា : ចាប់ខ្លួន ឈូក យោធាជើងចាស់នៃចលនាឥស្សរៈ និងជាគណៈកម្មាការប្រត្តិបត្តិតំបន់បូព៌ា ។

- ៣០ សីហា : កិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយ ថៃឡង់ ។

- ខែកញ្ញា : ផ្តើមចាត់ការសម្លាប់មនុស្សជាស្វ័យប្រវត្តិ ។

- ២៥ កញ្ញា : ចាប់ខ្លួន កែវ មាស ជើងចាស់នៃបក្សប្រជាជន យកទៅដាក់ទួលស្លែង ហើយស្លាប់នៅទីនោះ ១ខែក្រោយមក ។

- ២៧ កញ្ញា : នួន ជា ជានាយករដ្ឋមន្ត្រីជំនួស ប៉ុល ពត ។

-ថ្ងៃ ២៩ តុលា : ណៃ យ៉ានចាន់ដា បានសរសេរអត្ថបទនៅក្នុង Far Eartern Economic Review អំពីឧក្រិដ្ឋកម្មដែលកើតឡើងនៅកម្ពុជា ។

- ១ វិច្ឆិកា : ចាប់ខ្លួន នង សួន រដ្ឋមន្ត្រីក្រសួងកសិកម្ម ។

(តទៅលេខក្រោយ)

នាទី ព្រះពុទ្ធសាសនា

# ពុទ្ធប្បវត្តិអមដោយរូបភាព

## A Pictorrial Biography of Saky amuni Buddha

❖ រូបភាព និងរឿងដើមជាភាសាថៃ ដោយ គុណាប៉ាយុតា

❖ បកប្រែជាភាសាអង់គ្លេស ដោយ ហ្សឺត .អេ.លី

❖ ផាត់ពណ៌ដោយ យ៉ាន់ ហ្វាលី

❖បកប្រែជាភាសាខ្មែរដោយភិក្ខុ គង់ អាំ



❖ Original Illuatration and Naration in Thai by Gunapayuta.

❖ Translation into English by A Lu.

❖ Coloring by Yann Fang Lee

❖ Translation into Khmer by Bhikkhu Kong Am.

**៦៣**- មហាជនទាំងឡាយជ្រួលច្របល់តប់ប្រមល់យ៉ាងខ្លាំងដោយឃើញអាការៈហ៊ានហួសប្រមាណ ឥតមានកោតខ្លាចរបស់តាចាស់រូបនេះ ព្រោះនេះ ជាដំណើរយាងកម្សាន្តលើកទី១របស់រាជកុមារ ហើយព្រះរាជាទ្រង់បានចេញព្រះរាជប្រកាសហាមប្រាមមិនឱ្យឃើញមានមនុស្សចាស់ មានមនុស្សឈឺណាម្នាក់ឡើយនៅពេលដែលព្រះអង្គម្ចាស់យាងដល់ ។ ជនទាំងឡាយស្ទុះស្ទាប្រុងចូលទៅបញ្ឈប់ដំណើរតាចាស់ជរានោះ មិនឱ្យដើរទៅមុខទៀត ក៏ប៉ុន្តែវាហួសពេលណាស់ទៅហើយ ព្រោះព្រះអង្គទ្រង់ទតឃើញរួចជាមុនទៅហើយ ។

63- People were very much upset by the daring appearance of this old man since this was the prince's first excursion, and the king had issued an order prohibiting the presence of all old sick persons. They rushed to stop this old man from advancing further, intending to drive him home, but it was already too late. The prince had already seen him!



**៦៤**- ព្រះសិទ្ធត្ថ ទ្រង់ភ្ញាក់រន្ធត់យ៉ាងខ្លាំងនៅពេលបានឃើញមនុស្សចាស់នោះ ។ ព្រះអង្គទ្រង់ពុំស្គាល់ថា តើគេជាសត្វអ្វីឡើយ ។ ទ្រង់ឆ្ងល់ខ្លាំង ដូច្នេះ ក៏ទ្រង់សួរ **ឆន្នៈ** ជានាយសារថីថា "នែ **ឆន្នៈ**! តើនោះជាអ្វី? ជាមនុស្សមែនទេ? បើគាត់ជាមនុស្ស ហេតុអ្វីក៏ខ្នងគាត់កោងខ្លាំងម្ល៉េះ ? យ៉ាងម៉េចមិនត្រង់ដូចគេរាល់គ្នា ? ហេតុអ្វីបានជាគាត់ញាក់ញ័រយ៉ាងនេះ? រួចចុះសក់គាត់ហេតុអ្វីបានជាពណ៌សអ៊ីចឹង? តើភ្នែករបស់កើតអ្វី? តើធ្មេញគាត់បាត់ទៅណាអស់? ហើយមានមនុស្សប៉ុន្មាននាក់ទៀត ដែលមានអាការៈបែបនេះ? នែ **ឆន្នៈ**! ចូរឯងប្រាប់យើងមកតើវាយ៉ាងម៉េចហ្នឹង?" ។

64- Prince Siddhartha was quite surprised at the sight of the old man. He did not know what the creature was. So he asked his driver Chandaka; "Chandaka! What is that? A person? If he is a person, why is his back so curved and not as straight as other people's? Why does he shake? And the hair, why is it white? What happened to his eyes? Where are his teeth? Are some people born this way? Chandaka! Tell me what all this mean!"



(តទៅលេខក្រោយ)

*ទំព័រពាណិជ្ជកម្ម*

## លោកអ្នកមានជំងឺឫសដូងបាតឬ ?



ឫសដូងបាតក្នុង ? (Internal Pile) ឬឫសដូងបាតក្រៅ ? (External Pile) ជំងឺទាំងពីរនេះ គ្មានបញ្ហាទេ តែកុំទុកឱ្យយឺតពេលវានឹងអាចក្លាយជាដំបៅមហារីកលំបាកព្យាបាលណាស់ ហើយវាអាចបណ្តាលឱ្យស្លាប់បានទៀតផង ។ បើលោកអ្នកមានរងនូវការចាប់ឈឺផ្សាអួលណែនធ្លាក់ឈាមរាំរ៉ៃនេះជាទុក្ខវេទនាយ៉ាងយូរ ។ សូមលោកអ្នកទាក់ទងនឹងខ្ញុំបាទ **គីម ភឿន** ដែលអ្នកស្រុកក្បៀនស្វាយ បានឱ្យរហ័សនាមថា "**លោកគ្រូពេទ្យទេវតា ឬលោកគ្រូ ទេព្យឥសី**" ដោយសារខ្ញុំជួយអ្នកជម្ងឺទាំងនោះឱ្យជាសះស្បើយពីការចុកចាប់អួលផ្សាយ៉ាងសាកសិទ្ធិបំផុត ។ លោកអ្នកគ្រាន់តែប្រើថ្នាំបុរាណជប៉ុនផលិតតាមបែបសម័យទំនើប នោះអាចបានជាសះស្បើយដូចបំណង ។ ក្នុងពេលព្យាបាលអាចទៅធ្វើការធម្មតាមិនបាច់ឈប់សម្រាកអ្វីឡើយ ។ អាចជួបតាមទូរស័ព្ទពីម៉ោង ៧ ព្រឹក ដល់ម៉ោង ៦ ល្ងាច រាល់ថ្ងៃ សុក្រ សៅរ៍ អាទិត្យ ។ ពីម៉ោង ៣ ល្ងាច រាល់ថ្ងៃ ច័ន្ទ អង្គារ ពុធ ព្រហស្បត្តិ៍ ។ ខ្ញុំបាទជាគ្រូទេព្យទេវតា **គីម ភឿន**

KIM, Phien 421 E Mentor St. Philadelphia. PA 19120

Phone : **215 680 2059**

## ចំណីដែលទប់ទល់ជរាភាពដ៏ខ្លាំងជាងគេក្នុងលោក គឺទឹកផ្លែឈើ "គោជី" នៃព្រៃហេមពាន្ត




បើចង់បាន Goji មកពិសារសូមជាវតាម www.forever.freelife.com

ឬក៏ទូរស័ព្ទលេខ : **(267) 253-3947**

# ស្ត្រីខ្មែរដំបូងបង្អស់ដែលបានធ្វើដំណើរពីប្រទេសបារាំងមកភ្នំពេញតាមផ្លូវគោក

ដោយ : ពិន នារីពិទូ

•••ស្ត្រីពីររូបធ្វើដំណើរផ្សងព្រេងចម្ងាយជាង ១ម៉ឺនគីឡូម៉ែត្រពីទីក្រុងប៉ារីសមកភ្នំពេញ ។ ម្នាក់ជាខ្មែរ ម្នាក់ទៀតជាបារាំង បានបញ្ចប់ដំណើរដោយជោគជ័យ តែពុំទាន់មានសារព័ត៌មានខ្មែរមួយណាចុះផ្សាយពីដំណឹងដ៏អស្ចារ្យនេះនៅឡើយ ។ ពិទូ បានជួបនឹងអ្នកដំណើរទាំងពីរហើយ រំពឹងដំណើរនោះនៅឆ្នាំក្រោយមក :

ព្រះអង្គម្ចាស់ក្សត្រី ស៊ីសុវត្ថិ ស៊ីលីយ៉ា ជាស្រីខ្មែរដំបូងគេបង្អស់ដែលបានធ្វើដំណើរតាមរថយន្តផ្ទាល់ខ្លួនពីទីក្រុងប៉ារីសមកភ្នំពេញ ប្រកបដោយសុវត្ថិភាព ។ ជាធម្មតាការធ្វើដំណើរឆ្លងកាត់ពីទ្វីបមួយទៅទ្វីបមួយទៀត រមែងប្រព្រឹត្តិទៅតាមផ្លូវអាកាសដោយប្រើរយៈពេលខ្លី និងចំណាយថវិកាតិចជាង តើហេតុអ្វីបានជាព្រះអង្គម្ចាស់សំរេចចិត្តរៀបចំគម្រោងធ្វើដំណើរតាមផ្លូវគោកពីប្រទេសបារាំងមកកម្ពុជា ?

សូមរង់ចាំអានអត្ថបទនេះលេខក្រោយទៀត




សួស្តីឆ្នាំថ្មី

## Yoo's Auto Service and Collision

ឃូ បំរើសេវារថយន្ត
នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច

FREE ESTIMATES

យើងនឹងជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត តាមតែយើងធ្វើបាន ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។

COUPON
$10 OFF TOWARD EMISSION AND STATE INSPECTION

ផ្នែកជាងម៉ាស៊ីន
Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission
Inspection & Repairs
Muffler & More

ផ្នែកជួសជុលតួរថយន្ត
Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists




189 W. Duncannon Ave. Phila., PA 19120

ទូរស័ព្ទរក SAM 215-457-7777 ឬ 215-457-7779, Fax-215-457-7475



## ANGKOR AUTO SERVICE, INC.

ហាងជួសជុលរថយន្ត "អង្គរ"

4835 N. 16th Street. Philadelphia, Pa 19141
Tel : (215) 455-7810
Ricky : (215) 485-1425

Specializing in Body Kit and Custom Paint

ជំនាញខាងជួសជុលតួរថយន្ត
និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ

RICKY
Hand Ph.: Ricky 215-485-1425

មានបទពិសោធន៍២០ ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រ វាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អ៉ិនស៊ូរិន បានផង យើងផ្តល់សេវាគ្រប់យ៉ាង :

- -State inspection
- -Insurance Claims
- -Auto Glass Repairs
- -Auto Frame Repairs
- -Custom Painting
- -Auto A/C




បើកពីម៉ោង ៩ ព្រឹក ដល់ម៉ោង៥ល្ងាច ពីថ្ងៃចន្ទ ដល់ ថ្ងៃ សៅរ៍

ចុះតម្លៃជូន 10 % បើបង្ហាញប័ណ្ណពាណិជ្ជកម្មនេះ



From :Philadelphia



សួស្តីឆ្នាំថ្មី

ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

## Rathe`s Auto Service

State and Emission Inspection General Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY




-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : -ដូរប្រេងកឺរត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ពាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។

ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

# Yes you can!

... get free or low-cost health insurance for your children.

- Did you lose your health insurance when you lost your job?
- Do your children have no health insurance?
- Do you wonder how you'll afford your kids' next doctor visit?

AmeriChoice
A UnitedHealth Group Company

(215) 360-9841
Leap Thach

Your children deserve to be healthy.
AmeriChoice can help.



Repro Center
怡保印刷中心
the printer you can trust
Since 1993

- Fast, Easy Print Ordering
- Premium Quality
- Low Price
- Excellent Customer Service

T: 215.271.5041 /5042
1531-33 South 7th Street
Philadelphia • PA 19147
F.: 215.271.5043 • reprocenter@usa.net

BUSINESS CARDS as low as $15



## សេវាបោះពុម្ព

- តារាងម្ហូបភោជនីយដ្ឋាន
- លិខិតចម្លងគ្មានកាបូន
- កែអស័យដ្ឋាន
- ស្រោមសំបុត្រ
- ថតចម្លងពណ៌ឌីជីថល
- សេវាបញ្ញើលិខិត
- កាតាឡុកសៀវភៅ
- ខិតប័ណ្ណបត់ជាសៀវភៅ
- ខិតប័ណ្ណលាត
- រូបផ្ទាំងតូចៗ
- ផ្ទាំងរូបផ្ទាំងធំៗ
- ប្រតិទិន
- ធ្វើហ្វូលឌ័រសម្រាប់ផ្សាយ
- បកប្រែ
- គូសក្រាហ្វិក
- ធ្វើត្រាមាស
- អ៊ុតលើក្រប
- ធ្វើក្រប
- ប្រតិទិន
- បាក់លើក្រណាត់ ឬសូត្រ

**Services Products**

Restaurant Menu
Carbonless NCR Form
Business Cards
Envelopes
Letterhead
Digital Color Copy
Mailing Services

Catalogs / Booklets
Brochures
Flyers
Postcards
Posters
Calendars
Presentation Folder

Translation
Graphic Design
Gold Foil Stamping
Laminating
Labels
Clothing Embroidery / Silk Screen



## HOME FOR SALE

តំបន់ល្អជិតផ្សារ TWIN មាន Garage,
3Bedroom, 2 Baths តម្លៃថោកល្អ
នៅ NE. $129,999
5433 West Ford Rd. Northeast
Phila., PA 19120 សូមទាក់ទង
Mr.Vandy (215) 329-5183 or (267) 253-5845

មានជំនាញខាងទិញ.លក់ផ្ទះ.ពាណិជ្ជកម្ម. វិនិយោគ ហិរញ្ញវត្ថុ ឬជួល
ហើយស្វាគមន៍រាល់លោកអ្នកដែលធ្វើវិនិយោគ

Vinh Ho, 215-391-9516

Email: vho.realestate@consultant.com

ANCHOR Real Estate Development
320 Oregon Ave, #3B, Philadelphia, PA 19148

Specialize - Buy_Sell_Invest_Finance_Rent ...
Beginner-investors are welcomed!



# Danny's Café

សួស្តីឆ្នាំថ្មី

Foods & Hoagies

1. Beef Stew Serve with Bread..........................................នំប៉័ងខគោ
2. Curry Chicken Serve with Bread..........................នំប៉័ងការីសាច់មាន់
3. Curry Beef Saramann Serve with Bread................នំប៉័ងសាច់គោ ខការីសារាមាន់
4. Meatball Soup Serve with Bread ........................ស៊ុបប្រហិតជាមួយនំប៉័ង
5. Mi Siam ...............................................................មីសៀម








1730 Snyder Ave, Philadelphia, PA 19145 / Mon – Fri: 7am – 7pm Saturday: 9 am – 8 pm / Sunday : CLOSED
Tel: 215.467.4082 Fax: 215.467.4642 / Thank You, Please come again !

Kavei

ភោជនីយដ្ឋានខ្មែរ

320 OREGON AVENUE . PHILADELPHIA PA 19148 . 215-952-6688



នំបញ្ចុកសម្លខ្មែរ